# ចរិតឆ្កែ

ហួត សេងគៀ



សៀវភៅដែលធ្វើឱ្យយើងល្អជាងឆ្កែ

# មាតិកា

**ទំព័រដើម** 1-3

**ចរិតទីមួយ ស្មោះត្រង់** 3-20

**ចរិតទី២ ការពាររបស់ខ្លួនឯង** 21-51

**ចរិតទី៣ បើខាំមិនឈ្នះ មិនខាំតែម្តង** 52-62

**ទំព័រចុងក្រោយ** 63-64

**អំពីខ្ញុំ** 65



# ទំព័រដើម

ខ្ញុំមានបំណងសរសេរសៀវភៅនេះយូរមកហើយ គ្រាន់តែមិនច្បាស់ថា ត្រូវសរសេរវាជាចំណុចក្នុងសៀវភៅ ឬជាសៀវភៅដាច់តែឯងតែម្តង។ វាមិនវែងណាស់ណាទេ ដូច្នេះបើដាក់ជាផ្នែកណាមួយក្នុងសៀវភៅ ក៏ទំនងដែរ ប៉ុន្តែខ្ញុំចង់បានចំណងជើងនេះមកធ្វើជាសៀវភៅរបស់ខ្ញុំ។

ខ្ញុំក៏សម្រេចថាសរសេរជាសៀវភៅតែម្តង ដោយរៀបមាតិកានៅពេលខ្ញុំកំពុងធ្វើការ។ សៀវភៅនេះខ្លីទេ ដោយមានបីចំណុចធំ។ ខ្ញុំយកឆ្កែមកធ្វើជាការពន្យល់ក្នុងសៀវភៅនេះព្រោះឆ្កែជាសត្វចិញ្ចឹមដែលនៅជាមួយមនុស្សយូរមកហើយ។ ចរិតឆ្កែ គឺជាសៀវភៅដែលបង្ហាញពីអ្វីដែលយើងត្រូវធ្វើ ដើម្បីឱ្យខ្លួនឯងល្អជាងឆ្កែ។ យើងមានការគិត និងស្នាដៃជាច្រើនក្នុងលោក ប៉ុន្តែចរិតឆ្កែទាំងបីក្នុងសៀវភៅនេះ ជាកង្វះខាតរបស់មនុស្ស។

ដោយសារតែខ្ញុំជាប់ពាក្យជាមួយខាងរោងពុម្ពថា នឹងប្រគល់សៀវភៅថ្មីឱ្យគេក្នុងខែនេះ ខ្ញុំត្រូវសរសេរកូនសៀវភៅនេះឱ្យចប់ក្នុងពេលខ្លីបំផុត។ ខ្ញុំមិនអាចចែកពេលដើម្បីសរសេរសៀវភៅពីរក្នុងពេលតែមួយបានទេ ដូច្នេះមានតែទុកចោលមួយសិន ដើម្បីកុំឱ្យខកទាំងពីរ។ សៀវភៅនេះ គឺសម្រាប់ចែកជូនដោយឥតគិតថ្លៃ និងសម្រាប់អ្នកដែលចូលចិត្តអានសៀវភៅរបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំមិនមានចិត្តទូលាយដល់ថ្នាក់ទៅព្យាយាមផ្គាប់ចិត្តមនុស្សដែលមិនចូលចិត្តស្នាដៃខ្ញុំទេ។

បើសិនជាអ្នកទាំងអស់គ្នាចូលចិត្ត សូមយកវាមកអានម្តង

ហើយម្តងទៀត ដើម្បីរំលឹកខ្លួនឯង ព្រោះខ្ញុំគិតថា ចរិតទាំងបីនៅក្នុងសៀវភៅនេះ នឹងធ្វើឱ្យអ្នកទាំងអស់គ្នា ផ្លាស់ប្តូរខ្លួនឯងបាន។ ខ្ញុំនិយាយមែនទែន មិនមែននិយាយរបៀបបោកក្នុងសិក្ខាសាលាទេ។ ខ្ញុំមិនចង់រស់នៅជាមួយមនុស្សដែលមានចរិតមិនស្មើភ្លែនោះទេ។

# ចរិតទី១

# ស្មោះត្រង់

ក្នុងឆ្នាំ២០១៦ ខ្ញុំបានជួបមនុស្សមិនស្មោះត្រង់ជាច្រើននាក់។ ខ្ញុំជឿថា ខ្ញុំនឹងនៅតែជួបមនុស្សប្រភេទនេះបន្តទៅទៀត។ ដើម្បីកាត់បន្ថយ ខ្ញុំគ្មានមធ្យោបាយអ្វីផ្សេងដើម្បីធ្វើក្រៅពីសរសេរសៀវភៅនោះទេ ព្រោះខ្ញុំជាអ្នកនិពន្ធ។ ខ្ញុំនឹងព្យាយាមលើកតម្កើងភាពស្មោះត្រង់ឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន តែខ្ញុំមិនប្រាកដថា វានឹងអាចទៅរួចនោះទេ បើអ្នកដែលអានហើយ មិនយកទៅធ្វើ។

**ភាពស្មោះត្រង់ ជាមូលដ្ឋាននៃការរស់នៅរបស់យើង**។ បើយើងមិនស្មោះត្រង់នឹងគ្រួសារខ្លួនឯង មិនយូរនឹងឆាប់ទេ គ្រួសារនេះ នឹងត្រូវបែកបាក់គ្នា។ បើយើងមិនស្មោះត្រង់នឹងក្រុមហ៊ុនដែលយើងធ្វើការ មិនយូរទេគេនឹងដេញក្បាលយើងចេញ។ ប៉ះក្រុមហ៊ុនណាគេហ៊ានដែរ គេនឹងចុះផ្សាយឈ្មោះយើងនៅលើកាសែតទៀតផង។ នៅមានច្រើនទៀត ដែលយើងមិនអាចខ្វះភាពស្មោះត្រង់បាន។

ខ្ញុំចូលចិត្តនិយាយត្រង់ណាស់ ដូច្នេះខ្ញុំគិតថា ខ្ញុំក៏មានភាពស្មោះត្រង់ដែរ។ ខ្ញុំមិនចូលចិត្តនយោបាយ សាសនា អ្នកជំនួញ និងអ្នកសិល្បៈ ព្រោះមនុស្សទាំងនេះមិនមានភាពស្មោះត្រង់ក្នុងខ្លួនទេ។ ខ្ញុំគិតបែបនេះ ខ្ញុំក៏និយាយចេញមកបែបនេះ។ ចង់អ្នកណានិយាយអីក៏និយាយទៅ ខ្ញុំគ្មានអ្វីខុសទេ។ **បើគ្រាន់តែ**

និយាយពាក្យពិត ក៏ត្រូវគេចោទថាខុសដែរនោះ មនុស្សក្នុងលោកនឹងក្លាយជាអ្នកនយោបាយអស់ហើយ។

## ១-១ ឆ្កែ ជានិមិត្តរូបនៃភាពស្មោះត្រង់

ក្នុងចំណោមសត្វចិញ្ចឹមទាំងអស់ ឆ្កែ ជាសត្វដែលស្មោះត្រង់ជាងគេ។ តាមពិតទៅ វាមិនមែនស្មោះត្រង់ជាងសត្វផ្សេងទេ ប៉ុន្តែដោយសារមនុស្សនិយមចិញ្ចឹមឆ្កែជាងសត្វផ្សេង ទើបគេប្រើពាក្យ "ជាងគេ" នេះទៅ។ បើសិនជាយើងចិញ្ចឹមឆ្កែ ដោយចិត្តស្រលាញ់ វានឹងស្រលាញ់យើងតបវិញ តែបើយើងចិញ្ចឹមវាឱ្យតែបានៗ វាក៏នៅស្រលាញ់យើងវិញដែរ។ នេះ ជាចរិតឆ្កែ។

យើងអាចនឹងប្រើពាក្យខុសពីការពិតច្រើននៅក្នុងការរស់នៅ។ យើងប្រើពាក្យ **ឆ្កែ** ដោយសំដៅទៅលើមនុស្សណាដែលមានចរិតមិនល្អ ឬធ្វើរឿងមិនល្អ។ យើងមិនគួរប្រើពាក្យបែបនេះទេ ព្រោះឆ្កែជានិមិត្តរូបនៃភាពស្មោះត្រង់។ បើចង់ប្រើ សូមបន្ថែមពាក្យ "អាចម៍" នៅពីមុខមួយទៀត ទើបទំនងជាង ឬអាចប្រើពាក្យថា "អន់ជាងឆ្កែ" ក៏បានដែរ ដើម្បីបញ្ជាក់ន័យឱ្យកាន់តែច្បាស់។

សម្រាប់ខ្ញុំ វាមិនមែនជាបញ្ហាអីទេ ដែលមនុស្សណាម្នាក់ថា "អន់ជាងឆ្កែ"នោះ បើសិនជាមនុស្សនោះគ្មានភាពស្មោះត្រង់ដូចឆ្កែ។ ខ្ញុំនិយាយតាមអ្វីដែលខ្ញុំមើលឃើញប៉ុណ្ណោះ ហើយខ្ញុំក៏មិនឆ្កួតនឹងសុជីវធម៌នៃការនិយាយស្ដីដែរ ព្រោះ**សុជីវធម៌នេះត្រូវបានគេបង្កើតឡើងដើម្បីគ្រប់គ្រងមនុស្ស កុំឱ្យប្រើពាក្យមិនល្អទៅប្រមាថអ្នកដែលធំជាង**។ អ្នកធំទាំងនោះហើយ ដែលជាអ្នកចងក្រងសុជីវធម៌នេះ។

ពាក្យថា "អាចមិឆ្កែ" ឬ "អន់ជាងឆ្កែ" មិនមែនជាពាក្យប្រមាថទេ តែជាពាក្យសម្រាប់រៀបរាប់ពីលក្ខណៈរបស់មនុស្សប៉ុណ្ណោះ។ បើមនុស្សគ្មានភាពស្មោះត្រង់ បានន័យថា អន់ជាងឆ្កែហើយ ព្រោះឆ្កែដែលជាសត្វ បានប្រើភាពស្មោះត្រង់ដើម្បីរស់នៅជាមួយមនុស្សអស់មួយជីវិតវា។ **ការប្រមាថ មិនល្អទេ ប៉ុន្តែការប្រើពាក្យឱ្យចំៗ ជារឿងល្អ។**

យើងត្រូវបានសង្គមនេះ បង្រៀនមិនឱ្យប្រើពាក្យចំៗពេក ព្រោះវាអាចប៉ះពាល់ដល់អារម្មណ៍អ្នកដទៃ ដែលតាមពិតទៅគេសំដៅលើអារម្មណ៍អ្នកធំដែលគ្រប់គ្រងសង្គមនេះឯង។ គេមិនចង់ឱ្យនិយាយចំពាក្យ ព្រោះអាចធ្វើឱ្យគេបាត់បង់អ្វីដែលគេកំពុងមាន។ យើងដែលមិនបានគិត និងមិនចេះរើបម្រះ ក៏ព្រមតាមសង្គមនេះទៅ ហើយយើងក៏បាត់ភាពស្មោះត្រង់នៅក្នុងខ្លួនតាមរបៀបហ្នឹងដែរ។ **ឃើញសង្គមខុស កុំប្រឹងខុសតាមសង្គម ព្រោះនេះមិនមែនជារបៀបរស់នៅក្នុងសង្គមទេ។**

**ចំណុចចាប់ផ្តើមនៃភាពស្មោះត្រង់ គឺការប្រើពាក្យចំៗ និងចេញពីចិត្ត។** បើយើងគិតថា គំនិតគេល្អ ត្រូវប្រាប់គេថា ល្អ ដោយមិនចាំបាច់មានការតូចចិត្តនឹងខ្លួនឯងទេ។ អ្នកខ្លះមិនហ៊ានសរសើរអ្នកដទៃទេ ព្រោះខ្លាចខ្លួនអន់ជាងគេ។ ដោយសារខ្លាចអន់ជាងគេ ក៏ធ្វើឱ្យបាត់ភាពស្មោះត្រង់ ហើយទៅជាអន់ជាងឆ្កែវិញ។

ខ្ញុំបញ្ជាក់ម្តងទៀត **ឆ្កែជានិមិត្តរូបនៃភាពស្មោះត្រង់ ដូច្នេះសូមកុំយកឆ្កែទៅប្រៀបនឹងមនុស្សមិនស្មោះត្រង់។**

## ១-២ ភាពស្មោះត្រង់ នៅលើក្រដាស

នៅកន្លែងណាក៏មានស្តង់ដារពីរដែរ។ ការអប់រំក្នុងស្រុកយើងក៏មានស្តង់ដារពីរដូចគ្នា។ អ្វីដែលបង្រៀនផ្សេង ចំណែកអ្វីដែលយកមកប្រើផ្សេង។ នៅក្នុងសាលា រៀនតែទ្រឹស្តី ដល់ពេលចេញមកក្រៅ ត្រូវប្រើទ្រឹស្តីផ្សេងមួយទៀត។ ចុះការអនុវត្តវិញ? ការអនុវត្តមិនសូវខុសគ្នាទេ ព្រោះភាពស្មោះត្រង់ក្នុងសាលា ក៏មិនសូវមានដែរ។

**ភាពស្មោះត្រង់ មានតែនៅលើក្រដាសប៉ុណ្ណោះ ឬបានន័យថាគ្មានអ្នកណាយកមកប្រើទេ**។ កាលខ្ញុំរៀនថ្នាក់តូចៗ គ្រូបានបង្រៀនថាត្រូវនិយាយពាក្យពិត និងស្មោះត្រង់នឹងគ្នាក្នុងថ្នាក់។ សិស្សមិនអាចលួចរបស់អ្នកដទៃបានទេ ហើយសិស្សណាដែលលួចនឹងត្រូវគេចាប់ពិន័យ។ ប៉ុន្តែដល់ថ្នាក់កាន់តែធំទៅ ភាពស្មោះត្រង់ ក៏ត្រូវចុះថយ។

គ្រូដែលមកបង្រៀនគ្មានសមត្ថភាពបង្រៀន មានតែសញ្ញាបត្រពីស្រុកក្រៅហើយពូកែអួត។ នេះជាភាពមិនស្មោះត្រង់មួយបាត់ទៅហើយ។ តើមានគ្រូប៉ុន្មាននាក់ដែលហ៊ានប្រាប់សិស្សខ្លួនឯងថា “ខ្ញុំគ្មានសមត្ថភាពគ្រប់គ្រាន់ដើម្បីបង្រៀនទេ” នោះ? ខ្ញុំធ្លាប់ប្រាប់សិស្សរបស់ខ្ញុំបែបនេះ ក្នុងថ្នាក់ក្រាហ្វិចឌីហ្សាញ ចុងក្រោយសិស្សនោះក៏ឈប់មករៀន។ ខ្ញុំបាត់បង់សិស្សម្នាក់មែន តែខ្ញុំអាចរក្សាភាពស្មោះត្រង់របស់ខ្លួនឯងបាន។ ខ្ញុំរៀនចេះខ្លះពីការងារប៉ុណ្ណោះ តើឱ្យខ្ញុំគិតថាខ្លួនឯងចេះគ្រប់យ៉ាងម៉េចកើត? ខ្ញុំមិនភ្លើទៅកុហកខ្លួនឯងទេ។

ភាពស្មោះត្រង់ មានតែពាក្យប៉ុណ្ណោះ ព្រោះមនុស្សលែងឱ្យ

តម្លៃទៅលើវាយូរមកហើយ។ ហេតុអីបានជាគ្មានអ្នកណានិយាយពីបញ្ហានេះ? គឺដោយសារតែមនុស្សលែងមានភាពស្មោះត្រង់ដើម្បីទទួលស្គាល់ថា ខ្លួនឯងមិនស្មោះត្រង់។ **ភាពស្មោះត្រង់ ងាយនឹងបាត់បង់ណាស់ តែពិបាករក្សាជាប់ក្នុងខ្លួន។**

## ១-៣ ហេតុអ្វីបានជាមនុស្សគ្មានភាពស្មោះត្រង់?

**ទីមួយ គឺ យើងរៀនតាមអ្នកនយោបាយ និងអ្នកសិល្បៈច្រើនពេក។** មនុស្សសម័យនេះ សរសើរមនុស្សទៅតាមអ្វីដែលគេឃើញក្នុងកញ្ចក់ទូរទស្សន៍ប៉ុណ្ណោះ។ ទូរទស្សន៍ គឺជាកន្លែងដែលលុបបំបាត់ភាពស្មោះត្រង់ ដើម្បីប្រមូលផលចំណេញ។ អ្នកទាំងអស់គ្នា ឃើញពាណិជ្ជកម្មស្រាបៀរនៅតាមប៉ុស្តិ៍ទូរទស្សន៍ទេ? គេផ្សាយថា ‟ស្រាបៀរ ជាមោទនភាពជាតិខ្មែរយើង″។ សាកសួរខ្លួនឯងដោយត្រង់ទៅមើល តើយើងមានមោទនភាពដោយសារអី រាល់ថ្ងៃហ្នឹង? គ្រាន់តែរាប់ពាណិជ្ជកម្មក៏យើងដឹងថាទូរទស្សន៍ និងភាពស្មោះត្រង់ មិនដើរជាមួយគ្នាទៅហើយ។

ខ្ញុំនិយាយពីអ្នកនយោបាយ និងអ្នកសិល្បៈវិញ។ យើងកាន់តែរៀនតាមមនុស្សទាំងនេះកាន់តែច្រើន យើងកាន់តែដាច់ឆ្ងាយពីភាពស្មោះត្រង់។ អ្នកនយោបាយ ធ្វើគ្រប់យ៉ាងដើម្បីបក្ស និងដើម្បីខ្លួនឯង ប៉ុន្តែបែរជាកុហកថា ខ្លួនឯងធ្វើដើម្បីជាតិ។ ពួកគេមានវិធីសាស្ត្រផ្សព្វផ្សាយជាច្រើនរបៀប ប៉ុន្តែយើងអាចសរុបចូលគ្នាបាន គឺ **ធ្វើឱ្យប្រជាជនជឿបានហើយ កុំឱ្យប្រជាជនមានពេលគិត។** ការគិត អាចធ្វើឱ្យគេដឹងថា អ្នកណាស្មោះ

ត្រង់ ឬមិនស្មោះត្រង់បាន ហេតុនេះ**អ្នកនយោបាយខ្លាច ប្រជាជនដែលចេះគិត ប៉ុន្តែចូលចិត្តមនុស្សដែលពូកែថាតាម។**

ចំណែកអ្នកសិល្បៈវិញ គឺសម្តែង។ ពួកគេសម្តែងទាំងលើឆាក ក្រោយឆាក ក្រៅឆាក ក្រោមឆាក និងអត់ឆាក។ កន្លែងណាក៏សម្តែងបានដែរ ព្រោះនេះជាអាជីពរបស់ពួកគេ។ ការសម្តែងបានន័យថា គ្រប់យ៉ាងជាការរៀបចំទុកនិងមិនមែនជាការពិត។ តើអ្នកសិល្បៈណាដែលហ៊ាននិយាយថា 〝ខ្ញុំធ្វើដើម្បីលុយ〞 〝ខ្ញុំបោកទស្សនិកជនរាល់ពេលដែលខ្ញុំប្រាប់ថា ស្រលាញ់អ្នកទាំងអស់គ្នា〞 ឬ 〝ខ្ញុំជាមនុស្សមិនល្អ〞 ដែរទេ? គ្មានទេ។ សូម្បីតែអ្នកដែលក្បត់ប្តីប្រពន្ធឯង ក៏អាចសម្តែងធ្វើជាអ្នកដោះស្រាយរឿងគ្រួសារបានដែរ។

ទីពីរ គឺលុយ។ លុយ លុបភាពស្មោះត្រង់របស់មនុស្សបាន។ អ្នកដែលតាំងខ្លួនថាស្មោះត្រង់ ក៏អាចនិយាយកុហក ឬលើកជើងបានដែរ នៅពេលដែលត្រូវថ្លៃ។ មនុស្សខុសពីឆ្កែត្រង់ចំណុចនេះឯង។ មនុស្សស្រីម្នាក់ អាចត្រូវគេទិញដោយប្រើលុយបាន ហើយចុះចេញពីប្តីដែលការពេញច្បាប់ ប៉ុន្តែឆ្កែ ចង់អ្នកណាឱ្យអីវាស៊ីឆ្ងាញ់ ក៏វានៅតែរត់មកដេកនៅក្បែរជើងម្ចាស់វាវិញដដែល។ ខ្មាសឆ្កែ!

ទីបី គឺ តាមគ្នា។ នេះជាទម្លាប់របស់ខ្មែរយើងទៅហើយ។ ឃើញគេធ្វើអីច្រើន ក៏ទៅធ្វើដែរ ហើយបោកខ្លួនឯងថា ចូលចិត្ត។ មិត្តភក្តិខ្ញុំម្នាក់ ដែលចូលចិត្តលេងបាល់ទាត់បាននិយាយថា 〝ការកើនឡើងនៃអ្នកគាំទ្របាល់ទាត់ គឺកើតចេញពីការដោរតាមគ្នាប៉ុណ្ណោះ〞។ អ៊ីចឹងបានជាយើងឃើញមានពាក្យរិះគន់

អាក្រក់ជាច្រើនកើតឡើង នៅពេលដែលក្រុមបាល់ ទាត់ចាញ់គេ។ តើអ្នកគាំទ្រណាដែលរិះគន់ក្រុមបាល់ទាត់ខ្លួនឯង ពេលកំពុងបរាជ័យ? គឺអ្នកគាំទ្រដែលដោរតាមគ្នានេះឯង។ តាមពិតពួកនេះគ្មានទៅចូលចិត្តបាល់ទាត់ស្អីទេ។

មូលហេតុ អាចមានច្រើន តែហេតុផលធំ គឺមនុស្សខ្លួនឯងមិនចង់បានភាពស្មោះត្រង់។ គេអាចយល់ថា ភាពស្មោះត្រង់ គ្មានតម្លៃ។ អ្នកខ្លះគិតថា ភាពស្មោះត្រង់ស៊ីមិនកើត។ ខ្ញុំក៏ដឹងថា វាស៊ីមិនកើតដែរ អ៊ីចឹងហើយបានជាខ្ញុំប្រឹងរៀនជំនាញ ព្រោះជំនាញអាចស៊ីកើត ហើយមិនបាត់បង់ភាពស្មោះត្រង់ទៀត។ **មនុស្សដែលបាត់ភាពស្មោះត្រង់ មិនអាចមានចម្លើយដែលធ្វើឱ្យយើងទុកចិត្តបានទេ ដូច្នេះកុំខ្វល់ពីពួកនេះ។**

## ១-៤ ស្មោះត្រង់នឹងខ្លួនឯង

បើយើងចង់ចេះស្មោះត្រង់ជាមួយអ្នកដទៃ យើងត្រូវរៀនស្មោះត្រង់ជាមួយខ្លួនឯងសិន។ គ្រប់យ៉ាងចាប់ផ្ដើមពីខ្លួនយើងទៅទាំងអស់ មិនមែនតែភាពស្មោះត្រង់នោះទេ។ ប៉ុន្តែមនុស្សមួយចំនួនធំ បែរជាផ្ដោតទៅលើកត្តាខាងក្រៅច្រើនជាងខ្លួនឯង។

មានវិធីសាស្ត្រមួយ ដែលគេប្រើសម្រាប់បញ្ចប់កិច្ចការឱ្យបានទាន់ពេល គឺ ធ្វើរឿងពិបាកមុន ហើយចាំបង្ហើយរឿងងាយៗតាមក្រោយ។ វិធីនេះប្រើបានផលណាស់ ព្រោះក្រោយពេលយើងធ្វើរឿងពិបាកចប់ហើយ យើងនឹងកាន់តែមានកម្លាំងចិត្តដើម្បីធ្វើកិច្ចការបន្តទៀត។ បើយើងធ្វើរឿងងាយមុន យើងនឹងអស់កម្លាំងមុននឹងចូលដល់រឿងពិបាក ហើយយើងនឹងពន្យារពេលមិនខាន។

ភាពស្មោះត្រង់ជាមួយខ្លួនឯង ជារឿងពិបាកជាងគេ ហេតុនេះទើបយើងត្រូវធ្វើរឿងនេះមុនគេ។ នៅពេលយើងលែងបោកខ្លួនឯងហើយ ហ៊ាននិយាយការពិតពីខ្លួនឯងហើយ យើងនឹងអាចបង្ហាញភាពស្មោះត្រង់ចេញទៅខាងក្រៅបានដែរ។ **ភាពស្មោះត្រង់ ក៏ដូចជាមុខវិជ្ជាផ្សេងទៀត គឺត្រូវការពេលហ្វឹកហាត់។** យើងកាន់តែហ្វឹកហាត់យូរប៉ុណ្ណា យើងកាន់តែធ្វើវាបានល្អប៉ុណ្ណោះដែរ។

យើងអាចរកវិធីសាស្ត្របានយ៉ាងងាយ ដោយគ្រាន់តែស្វែងរកនៅលើអ៊ីនធឺណេតប៉ុន្មាននាទី។ ប៉ុន្តែខ្ញុំនឹងធ្វើឱ្យវាកាន់តែងាយទៀត ដោយដកស្រង់យកវិធីសាស្ត្របី ដែលយើងអាចចាប់ផ្ដើមធ្វើតលូវនេះបាន។

**វិធីទីមួយ គឺ ដឹងថាខ្លួនឯងពូកែខាងអី និងអន់ខាងអី។** ការដែលយើងដឹងពីខ្លួនឯងច្បាស់ យើងអាចស្មោះត្រង់នឹងខ្លួនឯងបានហើយ។ អ្នកខ្លះមិនហ៊ានទទួលស្គាល់ថា ខ្លួនមិនអាចធ្វើរឿងអ្វីមួយបានទេ។ គេនៅតែគិតថា ខ្លួនឯងចេះគ្រប់យ៉ាងដដែល ដែលនេះជាការបោកខ្លួនឯង។

**វិធីទីពីរ គឺតាមដានអារម្មណ៍របស់យើងឱ្យបានច្រើន។** អារម្មណ៍ជាផ្នែកមួយរបស់យើង ហេតុនេះបើយើងរំលងវាចោល យើងនឹងមិនដឹងថាខ្លួនឯងជាមនុស្សបែបណាទេ។ រាល់ពេលដែលយើងធ្វើអីមួយ យើងត្រូវទុកពេលបន្តិចដើម្បីគិតសិនថា យើងមានអារម្មណ៍បែបណា។ ក្រោយពេលដឹងហើយ យើងត្រូវហ៊ានទទួលស្គាល់អារម្មណ៍របស់ខ្លួនឯង។

ខាងរោងពុម្ពមិនយកសៀវភៅឱ្យខ្ញុំទាន់ពេល ហើយពេលខ្ញុំតេរសួរ គេឆ្លើយថា ភ្លេចថ្ងៃណាត់ និងថាសៀវភៅកាត់បិតមិនទាន់។ ខ្ញុំមានអារម្មណ៍ដូចត្រូវគេទះមួយកំភ្លៀង ហើយខ្ញុំទទួលស្គាល់ថាខ្ញុំខឹងខ្លាំងណាស់ ហើយចង់រករឿងរោងពុម្ពវិញទៀត តែពេលខ្ញុំបានទទួលសៀវភៅហើយ ខ្ញុំក៏ត្រលប់មកធម្មតាវិញ។

ខ្ញុំមិនកុហកខ្លួនឯងទេ បើខ្ញុំខឹង ខ្ញុំនឹងបញ្ចេញមកក្រៅភ្លាម ហើយខ្ញុំមិនចេះរកលេសដើម្បីដោះសារការពិតទេ។ ខ្ញុំតាមដានអារម្មណ៍ខ្លួនឯងគ្រប់ពេល សូម្បីតែមើលរឿងសិច ក៏ខ្ញុំគិតពីអារម្មណ៍ខ្ញុំដែរ ថារឿងណាដែលមើលហើយមានអារម្មណ៍រំភើបខ្លាំង។ ខ្ញុំស្មោះត្រង់ជាមនុស្សមួយចំនួនដែលមិនហ៊ាននិយាយពីរឿងនេះ។

**វិធីទីបី គឺហ៊ាននិយាយចេញក្រៅ**។ ភាពស្មោះត្រង់ បើលាក់ទុកតែក្នុងចិត្ត ហើយមិនហ៊ាននិយាយចេញមកក្រៅ ក៏គេមិនហៅថាស្មោះត្រង់ដែរ។ **ទាល់តែនិយាយពាក្យក្នុងចិត្តសិន ទើបយើងអាចស្មោះត្រង់នឹងខ្លួនឯងបាន**។

ខ្ញុំលើកឧទាហរណ៍មួយដែលទើបនឹងកើតឡើងនៅផ្ទះខ្ញុំ។ ខ្ញុំមានទន្សាយញីពីរក្បាលនៅផ្ទះ។ ល្ងាចមួយ ឪកូនសិស្សដែលមករៀនជាមួយម៉ាក់ខ្ញុំបាននិយាយប្រាប់ម៉ាក់ខ្ញុំ ពីរឿងបង្កាត់ទន្សាយនៅខាងក្រោមផ្ទះ ហើយខ្ញុំស្តាប់លឺ។ គេនិយាយថា "ចិញ្ចឹមទន្សាយដោយអត់ឱ្យវាមានកូន គឺធ្វើបាបវា ហើយជាតិក្រោយ បាបកម្មនេះនឹងរត់មករកយើងវិញ"។

ដល់ពេលខ្ញុំចុះមកក្រោម ម៉ាក់ខ្ញុំសួរថា "មានលឺគេនិយាយឬអត់"? ខ្ញុំថា "លឺហើយ ចុះកាលដែលគាត់ស៊ីសាច់សត្វរាល់ថ្ងៃមិនខ្លាចបាបទេ?" ម៉ាក់ខ្ញុំបម្រុងនឹងដើរចេញ ព្រោះដឹងថាខ្ញុំនឹងនិយាយអីបន្តទៀត។ ខ្ញុំនិយាយបន្ត ដោយប្រើសម្លេងកាន់តែខ្លាំងដើម្បីឱ្យគាត់លឺ "បើគាត់ធ្លាប់ងាប់ ហើយធ្លាប់ចាប់ជាតិមកវិញ ចាំមកនិយាយរឿងជាតិក្រោយជាមួយខ្ញុំ ។ ឱ្យគាត់ប្រដៅកូនគាត់ឱ្យល្អទៅ មិនបាច់មកប្រដៅអ្នកផ្សេងទេ"។

ម៉ាក់ខ្ញុំ ជឿលើសាសនា តែខ្ញុំអត់ទេ។ ខ្ញុំជឿលើខ្លួនឯង ហើយជឿថា សាសនា ជាហេតុផលដែលបំផ្លាញមនុស្ស ហើយខ្ញុំហ៊ាននិយាយរឿងនេះគ្រប់ពេល បើមានអ្នកណាយករឿងសាសនាមកនិយាយជាមួយខ្ញុំ។ ខ្ញុំមិនខ្វល់ថាគេគិតបែបណាមកលើខ្ញុំ តែខ្ញុំជឿលើភាពស្មោះត្រង់ ច្រើនជាងការធ្វើពុត។

ប្រើវិធីទាំងបីនេះទៅ អ្នកទាំងអស់គ្នានឹងមានភាពស្មោះត្រង់ជាមួយខ្លួនឯងមិនខាន។ កុំគិតថាវាស្រួលឱ្យសោះ។ អ្នកខ្លះរកតែចិត្តដើម្បីនិយាយពាក្យដែលខ្លួនចង់និយាយមិនបានផង។

## ១-៥ ស្មោះត្រង់នឹងអ្នកដទៃ

ក្រោយពីស្មោះត្រង់ជាមួយខ្លួនឯង យើងត្រូវចាត់ការជាមួយអ្នកដទៃទៀត។ តើស្មោះត្រង់ជាមួយអ្នកដទៃ បានប្រយោជន៍អ្វីមកវិញ? ខ្ញុំនឹកឃើញប្រយោជន៍តែមួយប៉ុណ្ណោះ គឺយើងមិនចាំបាច់ធ្វើពុតជាមួយអ្នកដទៃ។ ការធ្វើពុត ជារឿងពិបាក ព្រោះត្រូវរកនឹកពាក្យនិយាយបោកគេផង ហើយនៅខ្វល់ចិត្តខ្លាចគេដឹងទៀត។

ខ្ញុំមិនចាំបាច់ធ្វើពុតទេ។ អ្វីដែលអ្នកដទៃមើលឃើញ គឺជាចរិតខ្ញុំ។ ខ្ញុំជាមនុស្សឈ្លើយ តែមិនណាស់ណាទេ។ ខ្ញុំមិនគោរពអ្នកដទៃដោយសារតែគេមានអាយុច្រើនជាងខ្ញុំ ឬមានអំណាចធំនោះទេ។ ខ្ញុំគោរពតែអ្នកណាដែលមានស្នាដៃពិតប្រាកដប៉ុណ្ណោះ មិនមែនអ្នកបំប៉ោងស្នាដៃទេ។ នៅពេលដែលយើងរៀនចេះស្មោះត្រង់នឹងខ្លួនឯង យើងក៏អាចសម្គាល់មនុស្សដែលមិនស្មោះត្រង់បានដែរ។

យើងមិនបាច់ទៅប្រាប់គេពីលេខកូដ ATM ឬគម្រោងរកស៊ីរបស់យើង ដើម្បីបានឈ្មោះជាមនុស្សស្មោះត្រង់ទេ។ អ្វីដែលយើងត្រូវធ្វើ គឺកុំធ្វើពុត។ បើយើងជាមនុស្សបែបណា បង្ហាញឱ្យគេឃើញទៅ។ **សុខចិត្តឱ្យគេស្អប់អ្វីដែលជាខ្លួនយើងពិតប្រាកដ ប្រសើរជាងឱ្យគេចូលចិត្តអ្វីដែលមិនមែនជាខ្លួនយើង។** ពាក្យនេះមានគេយកមក Post នៅលើអ៊ីនធឺណេតច្រើន តែមិនដឹងថាមានគេចាប់អារម្មណ៍ឬអត់ទេ។

មុនពេលយើងនិយាយពាក្យក្នុងចិត្តជាមួយអ្នកដទៃ កុំភ្លេចប្រាប់គេមុនផង ដើម្បីឱ្យគេត្រៀមចិត្តឱ្យហើយ។ ទោះយើងមិននិយាយអ្វីអាក្រក់ក៏ដោយ តែការប្រាប់បែបនេះ ជារឿងល្អមួយព្រោះពេលយើងប្រាប់បែបនេះ គេអាចនឹងគិតថា គេមិនអាចស្ដាប់ពាក្យល្អពីយើងទេ ដូច្នេះគេក៏មិនរំពឹងពាក្យល្អដែរ។

កុំភ្លេច ត្រូវស្មោះត្រង់នឹងខ្លួនឯងមុន ចាំស្មោះត្រង់ជាមួយអ្នកដទៃតាមក្រោយ។ **កុំត្រង់ជាមួយគេ ហើយក្បត់នឹងចិត្តខ្លួនឯង។**

## ១-៦ ស្មោះត្រង់ និងភ្លើ

ខ្ញុំត្រូវលើកពាក្យពីរនេះ មកប្រៀបធៀបគ្នាសិន កុំឱ្យច្រឡំ។ **អ្នកដែលនិយាយថា មនុស្សត្រង់ ជាមនុស្សភ្លើ គឺជាមនុស្សដែលមិនគាំទ្រភាពស្មោះត្រង់ ឬខ្លាចភាពស្មោះត្រង់ផងក៏មិនដឹង។**

ភាពស្មោះត្រង់ ទាក់ទងនឹងចិត្តរបស់យើង ចំណែកភ្លើ គឺទាក់ទងនឹងខួរក្បាល។ ខួរក្បាលដែលមានទម្លាប់គិត នឹងអាចដោះស្រាយបញ្ហាបានដោយភាពស្មោះត្រង់ ហើយខួរក្បាលដែលគិតឃើញតែលុយ នឹងដោះស្រាយបញ្ហាដោយអំពើអាក្រក់ ប៉ុន្តែនឹងត្រូវពួកសារពត៌មានចុះផ្សាយសរសើរ។ ហេតុអី? ដោយសារតែសារពត៌មាន ក៏មិនគាំទ្រភាពស្មោះត្រង់ដែរ។

ឧទាហរណ៍ ខ្ញុំប្រាប់ម៉ាក់ខ្ញុំថា ខ្ញុំមិនទៅដាក់ពាក្យធ្វើការរដ្ឋទេ ព្រោះខ្ញុំគិតថា បុគ្គលិករដ្ឋ ជាកូនអុកនយោបាយជាប់បម្រុង ដែលត្រូវគេប្រើពេលណាក៏មិនដឹង។ ហើយខ្ញុំគិតទៀតថា នៅក្នុងនោះ អត់មានសេរីភាពដើម្បីនិយាយអ្វីទេ ក្រៅពីសរសើរមេខាងលើ។ ខ្ញុំនិយាយចេញពីការគិតរបស់ខ្ញុំ ហើយពូខ្ញុំថា អ្វីដែលខ្ញុំនិយាយនេះ គេហៅថាល្ងង់។ ល្ងង់? ដូចជាមិនមែនទេ។ ខ្ញុំនិយាយពាក្យពីចិត្តខ្ញុំ ក្រោយពេលខ្ញុំគិតមកយូរហើយ។ ខ្ញុំតាំងចិត្តយូរហើយថាមិនចូលធ្វើការរដ្ឋ តើមានអីខុស។

ឧទាហរណ៍មួយទៀត ចោរចូលប្លន់ក្នុងផ្ទះ ហើយសួរម្ចាស់ផ្ទះថា លុយទុកនៅកន្លែងណាខ្លះ។ ម្ចាស់ផ្ទះឆ្លើយតាមត្រង់ទាំងអស់ ហើយចោរក៏យកបានលុយយ៉ាងស្រួល។ នេះគេហៅថាល្ងង់។

**ត្រង់ និងល្ងង់ ខុសគ្នាទៅតាមកាលៈទេសៈ និងមនុស្សដែលយើងប្រើជាមួយ។** តើយើងត្រូវនិយាយអ្វីដែលយើងដឹងទាំង

អស់ដែរទេ បើភាគីម្ខាងទៀតមិនចង់ដឹង ឬនិយាយហើយធ្វើឱ្យខូចខាតធំពេក? ពេលនិយាយការពិត យើងច្បាស់ជាជៀសមិនផុតពីការបាត់បង់នោះទេ។ ជួនកាលអាចបាត់បង់លុយកាក់ មិត្តភក្តិ ឬឱកាស ប៉ុន្តែយើងត្រូវផ្ទៀងមើលដែរ ថាពេលណាដែលត្រូវស្មោះត្រង់ ហើយពេលណាត្រូវបិទមាត់ធ្វើមិនដឹង។

**មនុស្សត្រង់ មិនចាំបាច់ល្ងង់នោះទេ។** យើងអាចប្រើភាពស្មោះត្រង់បាន ដោយបណ្ដោយឱ្យខួរក្បាលធ្វើការបានតាមចិត្ត។

## ១-៧ ភាពស្មោះត្រង់ របស់មនុស្ស និងឆ្កែ

ដោយសារខួរក្បាលឆ្កែ មិនអាចគិតបានជ្រៅ និងរហ័សដូចមនុស្ស ឆ្កែប្រើភាពស្មោះត្រង់ក្នុងរបៀបល្ងង់ជាងមនុស្ស។ ឆ្កែស្មោះត្រង់នឹងម្ចាស់គ្រប់ពេលវេលា លើកលែងតែពេលវាឆ្កួត។ វាការពារម្ចាស់វា ពេលដែលមានរឿងអាសន្នអ្វីមួយកើតឡើង។ ដូច្នេះហើយ ទើបឆ្កែត្រូវបានគេចាត់ទុកមិត្តរបស់មនុស្ស។

ខ្ញុំធ្លាប់មើលវីដេអូមួយដែលប៉ូលីសចាប់បុរសម្នាក់ តែខ្ញុំមិនដឹងដោយសាររឿងអ្វីទេ។ នៅពេលនោះ ឆ្កែរបស់បុរសម្នាក់នោះបានព្យាយាមទាញដៃអាវម្ចាស់ ព្រោះវាដឹងថា គេកំពុងតែចាប់ម្ចាស់វាហើយ។ ភាពស្មោះត្រង់របស់ឆ្កែនេះ អាចមើលឃើញច្បាស់ណាស់ ទោះបីវីដេអូនោះខ្លីក៏ដោយ។ បន្ទាប់មកឆ្កែនោះទៅខាំប៉ូលីស ក៏ត្រូវប៉ូលីសបាញ់ងាប់បាត់ទៅ។

ឆ្កែសុខចិត្តលះបង់ជីវិតវា ទាំងវាមិនដឹងថា វានឹងត្រូវគ្រាប់ផង។ វាគិតមិនឃើញថា គេបាញ់វាទេ ប៉ុន្តែអ្វីដែលវាគិតឃើញ គឺ

ស្មោះត្រង់។ បើខ្ញុំអាចនិយាយភាសាឆ្កែបាន ប្រហែលជាខ្ញុំអាចសរសេរបានល្អជាងនេះ។

ប៉ុន្តែមនុស្សយើងខុសគ្នា។ យើងអាចជ្រើសរើសយកការបង្ហាញភាពស្មោះត្រង់បែបគ្រោះថ្នាក់ ឬបែបត្រូវគេធីបចោល។ យើងត្រូវជឿថា សង្គមនេះមិនចូលចិត្តភាពស្មោះត្រង់ទេ អ្វីដែលពួកគេនិយាយ គ្រាន់តែជាការសម្ដែងឱ្យអ្នកដទៃមើលប៉ុណ្ណោះ។ **បើយើងនិយាយត្រង់ ហើយប៉ះដល់អ្នកធំ យើងអាចនឹងគ្រោះថ្នាក់ដូចឆ្កែដែលនៅក្នុងវីដេអូអ៊ីចឹង។ តែបើយើងនិយាយត្រង់ តែមិនប៉ះពាល់អ្នកធំ យើងអាចនឹងត្រូវគេធីបចោលប៉ុណ្ណោះ។**

ខ្ញុំមិននិយាយប៉ះពាល់អ្នកណា ដូច្នេះខ្ញុំអាចស្មោះត្រង់បានដោយមានក្ដីសុខ តែមនុស្សនៅជុំវិញខ្លួនខ្ញុំ មិនសូវចូលចិត្តខ្ញុំទេ។ យើងអាចធ្វើខ្លួនស្មោះត្រង់ដូចឆ្កែបាន តែត្រូវកែកន្លែងខ្លះដើម្បីឱ្យសមស្របនឹងខ្លួនយើងជាមនុស្ស។ ត្រូវចាំថា នៅក្នុងសៀវភៅនេះ គឺដើម្បីធ្វើខ្លួនឱ្យល្អជាងឆ្កែ មិនមែនស្មើឆ្កែទេ ដូច្នេះត្រូវរកផ្លូវណាដែលឆ្កែរកមិនឃើញ។

## ១-៨ ស្មោះត្រង់ក្លែងក្លាយ

តើធ្វើយ៉ាងណាទើបយើងអាចដឹងថា អ្នកណាជាមនុស្សស្មោះត្រង់ក្លែងក្លាយ? យើងមិនអាចមើលភ្លាមដឹងភ្លាមនោះទេ ព្រោះភាពស្មោះត្រង់របស់មនុស្សត្រូវការពេលវេលាដើម្បីដឹង។ មិនថាអ្នកនោះពូកែលាក់យ៉ាងណាទេ គង់តែចេញចរិតពិតមកមិនខាន។ **ចរិតមិនស្មោះត្រង់ ប្រៀបដូចជាអាចម៍ដែលប្រឡាក់ខោអ៊ីចឹង មុនក្រោយគង់តែត្រូវគេឃើញ ឬធុំក្លិនមិនខាន។**

មនុស្សដែលស្មោះត្រង់ក្លែងក្លាយ អាក្រក់ជាងមនុស្សមិនស្មោះត្រង់ទៅទៀត។ វាស្រដៀងគ្នានឹង Cliton និង Obama ដែរ។ ម្នាក់ត្រូវបានមហាជនដឹងគ្រប់គ្នាថា ជាមនុស្សមិនស្មោះត្រង់ ចំណែកម្នាក់ទៀតត្រូវបានប្រព័ន្ធផ្សព្វផ្សាយជួយបិទបាំង និងព្យាយាមប្រាប់មហាជនថា ខ្លួនជាមនុស្សស្មោះត្រង់។

**បើជ្រុលធ្វើទៅហើយ ហេតុអីចង់ធ្វើក្លែងក្លាយ**? បើអ្នកទាំងអស់គ្នាមានលុយគ្រប់ដើម្បីទិញរបស់ original ប្រើហើយ តើអ្នកទាំងអស់គ្នាសុខចិត្តទិញរបស់copyប្រើទៀតទេ? យើងអាចធ្វើជាមនុស្សស្មោះត្រង់បានគ្រប់គ្នា ឱ្យតែយើងចង់ពិតប្រាកដ។

## ១-៩ ផ្លូវក្រោយរបស់ភាពស្មោះត្រង់

មេរៀនមួយដែលខ្ញុំមិនដែលភ្លេច ក្នុងរឿងសាមកុក គឺការទុកផ្លូវក្រោយជានិច្ច។ ភាពស្មោះត្រង់ ក៏ដូចគ្នាដែរ ត្រូវការផ្លូវក្រោយដើម្បីការពារជានិច្ច។ **ខ្ញុំមិនចង់ឱ្យមនុស្សស្មោះត្រង់ឆាប់ស្លាប់ពេកទេ ព្រោះបើបែបនេះ ពិភពលោកនេះ លែងមានមនុស្សស្មោះត្រង់ហើយ។**

ផ្លូវក្រោយ គឺតើពេលណាត្រូវបោះភាពស្មោះត្រង់ចោល? នៅពេលដែលបញ្ហាដល់ក (*ខ្ញុំមិនបញ្ជាក់ថាបញ្ហាអ្វីទេ*) យើងអាចបោះចោលភាពស្មោះត្រង់ជាមួយអ្នកដទៃ ហើយងាកមកស្មោះត្រង់តែជាមួយខ្លួនឯងបាន។ ជួនកាល អ្នកដទៃអាចនឹងប្រើភាពស្មោះត្រង់របស់យើងជាមួយគេនោះ មកវាយប្រហារយើងបាន ហេតុនេះយើងត្រូវឆ្លាតបន្តិច។

**កុំឱ្យភាពស្មោះត្រង់របស់ខ្លួនឯង មកបំផ្លាញខ្លួនឯង** ព្រោះបើយើងធ្វើបែបនេះ យើងនឹងក្លាយជាគម្រូអាក្រក់របស់ភាពស្មោះត្រង់។ នៅពេលអ្នកដទៃឃើញយើងបរាជ័យ ឬខាតបង់ដោយសារតែភាពស្មោះត្រង់ គេនឹងគិតថា ភាពស្មោះត្រង់ជារឿងមិនល្អ ហើយគ្មានអ្នកណាចង់ធ្វើជាមនុស្សត្រង់ទៀតទេ។

## ១-១០ រឿងខ្លី

គ្រួសារមួយ ទើបនឹងបានទិញផ្ទះថ្មី ហើយត្រូវរើចូលទៅនៅក្នុងថ្ងៃនេះ។ ពួកគេបានជញ្ជូនរបស់របរទាំងអស់ចូលទៅក្នុងផ្ទះថ្មី។ គ្រួសារនេះមានឆ្កែមួយក្បាល អាយុប្រហែលជា២ឆ្នាំ ដែលគេចិញ្ចឹមតាំងពីតូច។

នៅពេលមកដល់ផ្ទះថ្មី ម្ចាស់ផ្ទះលែងចង់ទុកឆ្កែនេះទៀតហើយ ព្រោះរំខានគាត់ និងមិនចង់ឱ្យប្រឡាក់ផ្ទះ។ គាត់បានដាក់វានៅខាងក្រៅផ្ទះរាល់ថ្ងៃ ដោយមិនរវល់រឿងចំណីវាទេ។ ឆ្កែនេះដោយមិនដឹងថាម្ចាស់មិនត្រូវការ វានៅដេកនៅជាប់មាត់ទ្វារដោយគិតថាម្ចាស់វាប្រហែលជារវល់ខ្លាំងណាស់ទើបគ្មានពេលចេញមកលេងជាមួយវា។

ដល់ល្ងាចបន្តិច ម្ចាស់វាក៏បើកទ្វារ ឆ្កែនេះក្រោកឡើងហើយបក់កន្ទុយដើរចូលផ្ទះ តែត្រូវម្ចាស់វាយកជើងបាំង ហើយទាញទ្វារបិទវិញ។ តាមពិតគេមិនមែនបើកទ្វារឱ្យវាចូលទេ គឺគេនាំកូនគេទៅដើរលេងនៅខាងក្រៅប៉ុណ្ណោះ។ ហើយក៏បានន័យថា ថ្ងៃនេះគេមិនបាយផ្ទះទេ។ ឆ្កែនេះត្រូវដេកអត់អីស៊ីពេញមួយថ្ងៃ។

ស្អែកឡើង ដោយទ្រាំនឹងការឃ្លានមិនបាន វាក៏ដើរទៅរកអីស៊ីនៅក្បែរនោះ។ វាទៅកាយថង់សម្រាមគេ ក៏ត្រូវគេយកឈើវាយចំក្បាល។ ឆ្កែនេះភ័យណាស់ ក៏រត់ត្រលប់មកផ្ទះក្នុងបំណងឱ្យម្ចាស់វាជួយ។ តែពេលមកដល់ វាក៏ត្រូវសម្លឹងមើលទ្វារដែលបិទជិតដដែល។ វាខំបញ្ចេញសម្លេងឱ្យម្ចាស់វាលឺ តែគេមិនចេញមកមើលវាទេ។

ឆ្កែនេះក៏ដាក់ខ្លួនដេកនៅជាប់នឹងមាត់ទ្វារទៀត ដើម្បីរង់ចាំម្ចាស់វា។ វាគិតថា ម្ចាស់វាមិនចោលវាទេ ព្រោះវាមិនដែលរត់ចោលម្ចាស់។ ប៉ុន្តែវាចាំក៏អត់ប្រយោជន៍ដែរ ព្រោះគេមិនបើកទ្វារឱ្យវាចូល ហើយក៏មិនយកបាយឱ្យវាស៊ីដែរ។

ប៉ុន្មានថ្ងៃក្រោយមក ឆ្កែនេះដើររកអីស៊ីតាមផ្លូវរាល់ថ្ងៃ ហើយតែងតែត្រលប់មកដេកមុខផ្ទះវិញជានិច្ច។ ម្ចាស់វាឃើញវា ក៏ធ្វើជាមិនឃើញ តែវានៅតែប្រឹងបក់កន្ទុយ និងរត់ទៅជិតជើងម្ចាស់វាដដែល។

នៅយប់មួយ វាកំពុងតែដេកនៅមុខផ្ទះធម្មតា ស្រាប់តែមានមនុស្សមួយក្រុមដើរមកក្បែរវា។ ពួកគេទើបនឹងចេញពីផឹកស៊ីស្រវឹងពេញផ្លូវ។ មនុស្សប្រុសម្នាក់ បានក្រឡេកឃើញឆ្កែដែលដេកនឹងដី ក៏នឹកចង់ស៊ីសាច់ឆ្កែ។ គេបានទាញដៃមិត្តភក្តិហើយចង្អុលទៅកាន់ឆ្កែ។

ឆ្កែនេះ ដោយសារអស់កម្លាំងស៊ីមិនឆ្អែតផង ហើយនឹកម្ចាស់វាទៀត ក៏មិនបានរត់ទៅណាដែរ។ មនុស្សមួយក្រុមនោះ បានចូលទៅព័ទ្ធឆ្កែនោះ ហើយចាប់វា។ គេចាប់ជើងវាបានម្ខាង ឆ្កែ

ក៏ស្រែកដើម្បីឱ្យម្ចាស់វាជួយ។ ម្ចាស់វាដែលនៅខាងក្នុងលឺហើយ តែខ្ជិលរវល់ព្រោះកំពុងតែដេកមើលទូរទស្សន៍។

គេចាប់ជើងវា ហើយបោកទៅនឹងជញ្ជាំងពីរដង។ សម្លេងស្រែករបស់ឆ្កែ ក៏ស្ងាត់ទៅវិញ។ មនុស្សមួយក្រុមនោះក៏ចេញទៅ ឆ្កែក៏បាត់ទៅ។ ព្រឹកឡើងម្ចាស់ផ្ទះបើកទ្វារមក ឃើញស្នាមបែកឈាមជាប់នឹងជញ្ជាំងផ្ទះ ក៏ដឹងថាមានរឿងអីកើតឡើង។ ពួកគេនិយាយថា "ឥលូវវាទៅហើយ យើងអាចបើកទ្វារអង្គុយមុខផ្ទះបានហើយ"។

# ចរិតទី២

# ការពាររបស់ខ្លួនឯង

កម្មសិទ្ធិផ្ទាល់ខ្លួន ជាក្តីស្រមៃរបស់មនុស្សគ្រប់គ្នា។ អ្នកណាក៏ចង់បានដែរ ប៉ុន្តែនៅពេលដែលបានហើយ មានអ្នកខ្លះមិនហ៊ានការពាររបស់ខ្លួនឯងទៀត។ ពេលយើងនិយាយអំពីកម្មសិទ្ធិផ្ទាល់ខ្លួន យើងអាចនឹងគិតដល់ទ្រព្យសម្បត្តិ ឬសម្ភារៈប្រើប្រាស់ផ្សេងៗ ប៉ុន្តែវាមានច្រើនលើសពីនេះទៀត។ វាអាចជាគំនិត ស្នាដៃ ជាតិសាសន៍ ឬជំនឿរបស់ខ្លួនឯង។ កម្មសិទ្ធិទាំងនេះ អាចមានតម្លៃលើសពីទ្រព្យសម្បត្តិទៅទៀត។

បើសិនជាមានហើយ យើងចាំបាច់ត្រូវតែការពារឱ្យបានល្អ កុំឱ្យគេមកលួចយកទៅ ឬធ្វើឱ្យខូច។ **របស់យើង នៅតែជារបស់យើង ដរាបណាយើងហ៊ានក្រោកឈរការពារ ពេលដែលមានគេចង់ប៉ះពាល់**។ ប៉ុន្តែបើយើងកំសាកទៃ ពេលបាត់ សូមកុំធ្វើជាស្តាយ។

ម៉ាក់ខ្ញុំតែងនិយាយប្រាប់ជានិច្ច ពីរឿងចោរលួចគាស់ផ្ទះ។ គាត់ប្រាប់ថា "យប់ឡើងមុននឹងដេក ត្រូវដើរមើលឱ្យគន្លឹះទ្វារ និងបង្អួចសិន ហើយមានចាក់សោរត្រឹមត្រូវហើយឬនៅ។ ឱ្យតែយើងប្រហែស គេចូលយកហើយ"។ នៅផ្ទះខ្ញុំដោយសារចោរធ្លាប់យកឈើឆ្កឹះគន្លឹះបង្អួច ម៉ាក់ខ្ញុំក៏យកលួសទៅចងបង្អួចរាល់យប់ដើម្បីការពារទ្រព្យ ។

បើនិយាយពីរឿងការពារ ឆ្កែនៅតែជាគម្រូល្អដដែល។ មនុស្សជាច្រើនចិញ្ចឹមឆ្កែដើម្បីការពារផ្ទះ។ បើនៅប្រទេសខ្លះវិញ ឆ្កែជាអ្នកការពារក្មេងទៀតផង។

## ២-១ ឆ្កែល្អចេះខាំចោរ

អ្នកដែលមានចិញ្ចឹមឆ្កែនៅផ្ទះ តែងតែមានគំនិតដូចគ្នាមួយ គឺឆ្កែអាចជួយការពារផ្ទះបាន។ មិនថាឆ្កែធំ ឬតឿទេ សុទ្ធតែអាចជួយរឿងនេះបានទាំងអស់។ បើឆ្កែធំ វាចេះហក់ខាំ តែបើឆ្កែតូច វាចេះព្រុសឱ្យដំណឹង។

នៅផ្ទះរបស់មិត្តភក្តិខ្ញុំ មានឆ្កែពីរក្បាល មួយធំ មួយតូច។ ឆ្កែធំនោះ គ្រាន់តែឃើញមនុស្សប្លែកមុខដើរចូលផ្ទះភ្លាម វានឹងរត់ចេញមកស្វាគមន៍ភ្លាម។ បើម្ចាស់វារត់មកឃាត់មិនទាន់ អ្នកដែលប្លែកមុខនោះ ដឹងតែជាប់ស្នាមចង្កូមវាមិនខាន។ ចំណែកឆ្កែមួយទៀតវិញ ខ្លាចមនុស្ស មិនហ៊ានមកជិតទេ។ វាព្រូសពីចម្ងាយបណ្ដើរ រត់ទៅក្នុងផ្ទះវិញបណ្ដើរ។ ឆ្កែទាំងពីរនេះ អាចការពារផ្ទះបាន ព្រោះមួយចាំព្រុស មួយទៀតចាំខាំ។ បើអាធំនោះមិនដឹងថាមានគេចូល អាតូចអាចជួយព្រូសហៅបាន។

នៅម្ដុំផ្ទះខ្ញុំ សម្បូរចោរគាស់ផ្ទះណាស់ ដូច្នេះរាល់យប់ពេលដែលមានឆ្កែព្រូស ខ្ញុំដឹងថាពួកនេះកំពុងធ្វើការងារហើយ។ អ្នកខ្លះថា ឆ្កែឃើញខ្មោចទើបវាព្រូស។ ខ្ញុំមិនគិតអ៊ីចឹងទេ ព្រោះឱ្យតែយប់ណាមានឆ្កែព្រូសខ្លាំង យប់នោះដឹងតែមានគេបាត់អីមិនខាន។ មិនថាកុំព្យូទ័រ ទូរស័ព្ទ ឬម៉ូតូទេ ឱ្យតែប្រហែស គឺបាត់។ កាលឆ្នាំមុនៗនោះ មានអ្នកបាត់ខោអាវទៀត។

អ្នកដែលមានឆ្កែក្នុងផ្ទះ អាចដឹងថាមានរឿងអីកើតឡើង ព្រោះឆ្កែមានត្រចៀកវៃជាងមនុស្ស ហើយមានចិត្តការពាររបស់ម្ចាស់វាទៀតផង។

## ២-២ ហេតុអ្វីត្រូវការពាររបស់ផ្ទាល់ខ្លួន?

**មូលហេតុទីមួយ គឺ ដើម្បីបញ្ជាក់ថាយើងជាម្ចាស់**។ ម្ចាស់កម្មសិទ្ធិ ត្រូវតែការពាររបស់ខ្លួនឯង ទើបអ្នកដទៃទទួលស្គាល់ថាយើងជាម្ចាស់។ កីឡាករជើងឯង ត្រូវការពារខ្សែក្រវ៉ាត់របស់ខ្លួនដើម្បីបញ្ជាក់ថា គេជាម្ចាស់ពិតមែន ឬគេមានសមត្ថភាពដើម្បីកាន់ខ្សែក្រវ៉ាត់នេះពិតមែន។

**មូលហេតុទីពីរ គឺដើម្បីធ្វើឱ្យរបស់យើងកាន់តែមានតម្លៃ**។ ឧទាហរណ៍ ស្នាដៃរបស់យើងត្រូវគេមើលងាយ ឬវាយតម្លៃខុស ដូច្នេះក្នុងនាមយើងជាម្ចាស់ស្នាដៃត្រូវបកស្រាយ ការពារស្នាដៃរបស់យើង កុំឱ្យធ្លាក់កូដដោយសារតែការវាយតម្លៃរបស់អ្នកដទៃ។ **អ្វីក៏ដោយ កាន់តែមានការការពារច្រើន កាន់តែមានតម្លៃ**។ នំដែលមានកញ្ចប់ការពារពីក្រៅ ច្រើនតែលក់ថ្លៃជាងនំដែលគ្មានកញ្ចប់។

**មូលហេតុទីបី គឺដើម្បីភាពក្លាហានរបស់យើង**។ មនុស្សដែលមិនហ៊ានការពាររបស់ខ្លួនឯង ជាមនុស្សកំសាក។ ការការពាររបស់ខ្លួនឯង គឺជាការហ្វឹកហាត់ភាពក្លាហានរបស់យើង។ យើងកាន់តែការពារប៉ុណ្ណា យើងក៏កាន់តែរឹងប៉ឹងប៉ុននោះដែរ។ ជើងឯកដែលការពារខ្សែក្រវ៉ាត់ច្រើនដង នឹងកាន់តែខ្លាំងជាងមុន ហើយយល់ពីភាពខុសគ្នារវាងការប្រកួតធម្មតា និងការប្រកួតយកជើងឯក។

**មូលហេតុទីបួន គឺដើម្បីឱ្យខ្លួនយើងល្អជាងឆ្កែ។** នេះជាមូលហេតុធំជាងគេក្នុងសៀវភៅនេះ។ ឆ្កែចេះការពាររបស់វា ចុះបើយើងមិនចេះ យើងមិនអន់ជាងឆ្កែទៅហើយ?

## ២-៣ ការពារជំនឿរបស់ខ្ញុំ

ជំនឿ ជារបស់ដែលខ្ញុំមានផ្ទាល់ខ្លួន ហើយក៏ជាអ្នកកំណត់ភាពខុសគ្នារវាងខ្ញុំ និងមនុស្សជុំវិញដែរ។ ជំនឿ ជាផ្នែកមួយនៃជីវិតរបស់មនុស្សដែលមិនអាចអត់បាន។ **គ្មានអ្នកណាម្នាក់ដែលគ្មានជំនឿនោះទេ។** អ្នកខ្លះគិតខុសថា នៅពេលដែលគេមិនជឿលើសាសនា ឬព្រះនឹងធ្វើឱ្យគេជៀសផុតពីជំនឿ ប៉ុន្តែជំនឿនៅតែមានក្នុងខ្លួនគេជានិច្ច។

ខ្ញុំមិនជឿលើសាសនាទេ។ មិនមែនខ្ញុំមិនចូលចិត្តពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនានោះទេ ប៉ុន្តែខ្ញុំមិនជឿលើក្បាច់ក្បូរដែលគេនាំគ្នាធ្វើ។ មានពាក្យប្រៀនប្រដៅមួយចំនួនក្នុងព្រះពុទ្ធសាសនា ដែលអាចធ្វើឱ្យមនុស្សមានការផ្លាស់ប្តូរបាន ដូចជាវិធីទប់កំហឹង វិធីសាងខ្លួនឯងឡើងវិញ និងការគោរពឪពុកម្តាយជាដើម។ ខ្ញុំធ្វើតាម ប៉ុន្តែបើសួរខ្ញុំថា ជឿលើបាបបុណ្យឬអត់ ខ្ញុំអត់ទេ។ **លើលោកនេះ គ្មានបាប ឬបុណ្យអ្វីទេ ប៉ុន្តែយើងនៅតែត្រូវធ្វើរឿងល្អដដែល។**

យើងមិនមែនល្អដោយសារតែយើងមានសាសនានោះទេ។ បើយើងគិតបែបនេះ បានន័យថា យើងយកសាសនាមកបាំងមុខដើម្បីលាក់បាំងរឿងអាក្រក់របស់យើងហើយ។ នេះជាទង្វើរបស់អ្នកនយោបាយប៉ុណ្ណោះ យើងមិនត្រូវធ្វើតាមទេ ប្រយ័ត្នគេរករឿង ព្រោះអ្នកនយោបាយស្អប់អ្នកណាដែលធ្វើអីកាត់មុខ

ពួកគេណាស់។ **អ្នកនយោបាយមិនដែលផ្ដាច់ខ្លួនពីសាសនាទេ ហើយមានអ្នកនយោបាយខ្លះទៀត អួតហួសដល់ថ្នាក់ចាត់ទុកខ្លួនជាអាទិទេពអីទៀត។** ហេតុតែចង់ឱ្យគេឱនក្បាលគោរពដូច្នេះក៏យកសាសនាមកធ្វើជាលេស។

ក្រៅពីជំនឿដែលមិនខ្វល់ពីសាសនា ខ្ញុំនៅមានជំនឿផ្សេងទៀតដែលនៅជាប់នឹងខ្លួនខ្ញុំ។ ជំនឿដែលខ្ញុំមានយូរជាងគេនោះ គឺខ្ញុំជឿលើការអានសៀវភៅ និងការស្រាវជ្រាវដោយខ្លួនឯង។ អ្វីដែលខ្ញុំមិនច្បាស់ ឬមិនចេះ ខ្ញុំទៅរកសៀវភៅមកអានជានិច្ច។ ខ្ញុំជឿថា សៀវភៅអាចផ្ដល់ចម្លើយឱ្យខ្ញុំបានលម្អិតជាងអ៊ីនធឺណេត គ្រាន់តែវាមិនចេញចម្លើយមកភ្លាមប៉ុណ្ណោះ។ ជំនឿនេះ បានជួយឱ្យខ្ញុំក្លាយជាអ្នកនិពន្ធសៀវភៅបានដូចអ្វីដែលខ្ញុំតែងតែស្រមៃ។ មានតែជំនឿនេះទេ ដែលខ្ញុំមិនដែលបោះបង់ចោល ហើយវាក៏មិនបោះបង់ចោលខ្ញុំដែរ។ ជំនឿលើការអាននេះ មិនពិបាកដូចជំនឿសាសនាទេ។ អ្វីដែលយើងត្រូវធ្វើ គឺយកចិត្តទុកដាក់អាន រួចយកមកគិតតែប៉ុណ្ណឹង។

ខ្ញុំនៅមានជំនឿមួយទៀត ដែលទើបនឹងចាប់ផ្ដើមក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ។ ខ្ញុំជឿថា សត្វទាំងអស់សុទ្ធតែចង់រស់ ដូច្នេះខ្ញុំមិនសម្លាប់វា មិនស៊ីសាច់វា និងមិនធ្វើបាបវាទាំងអស់។ មនុស្សដែលធ្វើបាបសត្វ ជាមនុស្សកំសាក ព្រោះធ្វើបាបបានតែអ្នកដែលគ្មានកម្លាំងតបវិញប៉ុណ្ណោះ។ បើវាខ្លាំងណាស់ ទៅធ្វើបាបថៅសម្ដេចទៅ ដឹងគ្នាហើយ។ ជំនឿនេះ បានផ្លាស់ប្ដូររបបអាហាររបស់ខ្ញុំ និងការប្រើប្រាស់សម្ភារៈផ្ទាល់ខ្លួន។ ខ្ញុំតមសាច់គ្រប់ប្រភេទ ហើយជៀសវាងមិនទិញផលិតផលណា

ដែលធ្វើអំពីសត្វ។ ខ្ញុំសុខចិត្តមិនពាក់ខ្សែក្រវ៉ាត់ ព្រោះខ្ញុំមិនចេះមើលថា ខ្សែក្រវ៉ាត់ណាស្បែក ឬមិនធ្វើពីជ័រទេ។

ខ្ញុំធ្វើការជាមួយជនជាតិអូស្ត្រាលីម្នាក់ ដែលគាត់ជឿលើសាសនាគ្រិស្ត។ ថ្ងៃមួយ ខ្ញុំបានទៅក្រៅញ៉ាំបាយជាមួយគាត់។ គាត់បានប្រាប់ខ្ញុំថា គាត់មិនញ៉ាំសាច់ជ្រូកទេ ព្រោះនៅក្នុងគម្ពីរសាសនារបស់គាត់មិនអនុញ្ញាតឱ្យញ៉ាំសាច់ជ្រូក។ គាត់អាចញ៉ាំបានដូចជា សាច់មាន់ ត្រី ឬសាច់សត្វដទៃទៀត។ គាត់ប្រាប់ថា ព្រះជាម្ចាស់របស់គាត់ បានកំណត់ថា សត្វណាដែលត្រូវតែសម្លាប់ដើម្បីធ្វើជាអាហារ។ សម្រាប់ខ្ញុំ បើព្រះមានចរិតបែបនេះ ខ្ញុំមិនអាចហៅថាព្រះបានដែរ ព្រោះលម្អៀងពេក។ **ឱ្យតែមានជីវិត គឺចង់រស់ហើយ**។ ព្រះមកពីណាស្អីក៏ធំខ្លាំងម្ល៉េះ អាចកំណត់អាយុជីវិតរបស់គេបានទៀត? ខ្ញុំមិនជឿព្រះរបៀបនេះទេ។

ចំណែកនៅក្នុងព្រះពុទ្ធសាសនាវិញ ក៏មានសីលមួយដែរ ដែលហាមមិនឱ្យសម្លាប់ជីវិតសត្វដទៃ ប៉ុន្តែនៅពេលដែលខ្ញុំទៅវត្ត ខ្ញុំឃើញម្ហូបដែលព្រះសង្ឃឆាន់ មានសុទ្ធតែសាច់ ហើយសាច់ខ្លះនៅជាប់ឈាមទៀតផង។ ទោះបីជាព្រះសង្ឃទាំងនោះមិនបានសម្លាប់ដោយខ្លួនឯងក៏ដោយ ក៏នៅតែមិនត្រូវដែរ។ ឬក៏សីលក្នុងសាសនាក៏មានចំណុចប្រហោងដូចច្បាប់ដែរ? បើបែបនេះមែន គឺត្រូវហើយ ព្រោះសាសនាក៏ត្រូវមនុស្សបង្កើតឡើងដែរ។ មនុស្សចូលចិត្តបង្កើតច្បាប់វិន័យដែលមានចន្លោះប្រហោង ព្រោះងាយស្រួលក្នុងការល្មើសច្បាប់ទាំងនោះ។ ខ្ញុំមិនថ្វាយបង្គំព្រះសង្ឃទៀតទេ តាំងពីខ្ញុំមានជំនឿបែបនេះ

ព្រោះខ្ញុំគិតថា **ជង្គង់មនុស្សប្រុសមិនលុតចំពោះមុខមនុស្សដែលខ្លួនឯងមិនឯកភាពនោះទេ។**

ខ្ញុំចូលចិត្តសត្វ រហូតដល់ខ្ញុំមិននិយាយជាមួយមនុស្ស ហើយទុកពេលទៅនិយាយជាមួយទន្សាយរបស់ខ្ញុំ។ ខ្ញុំមិនកុហកទេ មនុស្សខ្លះ មិនស្មើនឹងសត្វដែលខ្ញុំចិញ្ចឹមផង។

ខ្ញុំជឿថា មនុស្សក៏ជាសត្វដែរនៅលើផែនដីនេះ ដូច្នេះបើមនុស្សអាចរស់នៅបាន សត្វក៏អាចរស់នៅបានដែរ។ **ភាពអាត្មានិយម ការខ្លាចផុតពូជ និងខួរក្បាលភ្លឺភ្លើ បានធ្វើឱ្យមនុស្សមានគំនិតយកសត្វដទៃមកធ្វើជាអាហារ។** មិនទាន់អស់ទេ នៅពេលដែលមនុស្សកើតមកក្រោយៗ មិនដឹងខ្យល់អី ហើយមិនចេះឆ្ងល់អ្វីដែលកំពុងកើតឡើង អាហារនេះក៏ក្លាយជាតម្រូវការមួយដែលត្រៀមនឹងជួបការខ្វះខាត។ មានការស្រាវជ្រាវមួយបាននិយាយថាក្នុងឆ្នាំ ២០៤៨ សមុទ្រនឹងលែងមានត្រីទៀតហើយ ព្រោះការនេសាទហួសហេតុពេក។ **ចំណុចមួយដែលមនុស្សមិនអាចញែកខ្លួនពីសត្វបាន គឺការធ្វើតាមគ្នាដោយមិនចេះឆ្ងល់។**

ជំនឿធំជាងគេរបស់ខ្ញុំ គឺជឿលើខ្លួនឯង។ ខ្ញុំមិនមែននិយាយពីអំណួតទេ ប៉ុន្តែខ្ញុំដឹងថា **បើខ្ញុំចង់បានអ្វីមួយ ខ្ញុំត្រូវធ្វើដោយខ្លួនឯង។** បើខ្ញុំចង់ធ្វើការផ្នែកក្រាហ្វិចឌីហ្សាញ ខ្ញុំត្រូវរៀនជំនាញនេះដោយខ្លួនឯង ព្រោះគ្មានអ្នកណាមានពេលមកបង្រៀនយើងដល់ផ្ទះនោះទេ។ បើខ្ញុំចង់មានសៀវភៅផ្ទាល់ខ្លួន ខ្ញុំត្រូវសរសេរដោយខ្លួនឯង ព្រោះខ្ញុំគ្មានលុយជួលគេមកសរសេរឱ្យទេ។ បើខ្ញុំចង់ទៅដើរលេង ខ្ញុំត្រូវរកលុយ និងសន្សំដោយខ្លួន

ឯង ព្រោះម៉ាក់ខ្ញុំគ្មានលុយច្រើនឱ្យខ្ញុំយកទៅចាយនៅស្រុកគេទេ។ គ្រប់យ៉ាងដែលខ្ញុំមាន ឬចង់មាន ចេញពីខ្លួនខ្ញុំទាំងអស់។

ជំនឿនេះ ជាចំណុចសំខាន់ក្នុងការរស់នៅ។ បើយើងមិនជឿលើខ្លួនឯងទេ អ្វីក៏មិនអាចកើតឡើងបានដែរ។ **អ្នកខ្លះសុខចិត្តជឿលើព្រះ តែមិនជឿលើខ្លួនឯងក៏មានដែរ**។ ខ្ញុំក៏ធ្លាប់ជឿលើព្រះដែរ ហើយធ្លាប់បន់ស្រន់រាប់មិនអស់ តែមិនដែលបានអីមកវិញទេ ដូច្នេះជម្រើសចុងក្រោយរបស់ខ្ញុំ គឺខ្លួនឯងនេះហើយ។ នៅពេលយើងជឿលើខ្លួនឯង យើងនឹងរៀនធ្វើការដោយខ្លួនឯង ឈប់ចាំគេជួយ ឈប់ចាំឱកាសមកដល់ និងឈប់ដេករិះគន់គេដូចមនុស្សអត់ប្រយោជន៍មួយចំនួនទៀត។

ខ្ញុំមិនត្រឹមតែមានជំនឿទាំងនេះទេ ខ្ញុំការពារវាទៀតផង។ វិធីការពារជំនឿរបស់ខ្ញុំ គឺមិនទៅឈ្លោះជាមួយអ្នកដែលមានជំនឿផ្សេងពីខ្ញុំ។ ជំនឿ មិនមែនជារឿងត្រូវឈ្លោះគ្នាទេ នេះជារឿងឯកជន។ **បើយកជំនឿមកឈ្លោះគ្នា វាប្រៀបដូចជាវាស់ទំហំប្រដាប់ ហើយថាឱ្យគ្នាទៅវិញទៅមកអ៊ីចឹង**។ ជំនឿ ជារបស់ផ្ទាល់ខ្លួន ដូច្នេះមិនពាក់ព័ន្ធនឹងអ្នកណាទាំងអស់។ គេជឿលើសាសនា ជារឿងរបស់គេ ខ្ញុំជឿលើខ្លួនខ្ញុំ ក៏ជារឿងខ្ញុំដែរ។ **នៅពេលយើងយល់ច្បាស់ពីជំនឿ យើងនឹងរៀនចេះមេរៀនមួយ គឺក្បាលរបស់ខ្ញុំ មិនទើបក្បាលរបស់អ្នកណាទាំងអស់។**

បើសិនយើងមានជំនឿក្នុងខ្លួនហើយ សូមកុំឱ្យវាបាត់បង់ ព្រោះជំនឿ អាចធ្វើឱ្យយើងក្លាហានបាន និងជួយរកមធ្យោបាយក្នុងពេលលំបាកបានទៀតផង។ **ប៉ុន្តែខ្ញុំមានពាក្យមួយចង់ប្រាប់ មុននឹងចាត់ទុកវាជាជំនឿ សូមគិតផង។ កុំជឿមុនគិត ព្រោះពេល**

ដែលជឿហើយ ខួរក្បាលយើងនឹងផ្អៀងទៅខាងជំនឿនោះមិនខាន ហេតុនេះយើងគិតមិនចេះអីទេ។ គិតឱ្យអស់ចិត្ត ចាំជឿ ក៏មិនខាតពេលដែរ។

## ២-៤ ការពារសៀវភៅរបស់ខ្ញុំ

ខ្ញុំជាអ្នកនិពន្ធ ដូច្នេះអ្វីដែលខ្ញុំមានជាកម្មសិទ្ធិគឺសៀវភៅ។ ខ្ញុំសរសេរសៀវភៅចប់ប៉ុន្មានក្បាលដែរ ហើយក៏បានដាក់ឱ្យគេអាន free នៅលើអ៊ីនធឺណេត ព្រោះខ្ញុំគ្មានលុយបោះពុម្ពលក់ ហើយក៏គ្មានអ្នកណាស្គាល់ថា ហួត សេងគៀ ជាស្អីផង។ ទោះបីសៀវភៅទាំងនោះ មិនមែនទុកលក់មែន តែខ្ញុំមិនបានធ្វើឱ្យរួចពីដៃដូចរោងពុម្ពភាគច្រើននោះទេ។ ខ្ញុំរៀបពាក្យតាមល្បះច្បាស់ណាស់។ បើត្រង់ណាមិនល្អ ខ្ញុំសុខចិត្តលុបចោល។

ក្នុងសៀវភៅមួយក្បាល ខ្ញុំត្រូវចំណាយពេលយ៉ាងតិចបំផុតក៏មួយខែដើម្បីសរសេរឱ្យចប់។ សៀវភៅដែលខ្ញុំសរសេរយូរជាងគេ គឺ រៀនតាមឆាវឆាវ ដែលចំណាយពេលដល់ទៅបួនខែ ហើយសរសេរអត់ចប់ទៀត។ ខ្ញុំកំពុងត្រៀមសរសេរសៀវភៅនេះឱ្យចប់ ហើយរុញទៅឱ្យខាងរោងពុម្ពជួយបោះផ្សាយក្នុងឆ្នាំនេះ ព្រោះខ្ញុំចង់ឱ្យគេឃើញថា សៀវភៅសាមកុករបស់ខ្ញុំ ល្អជាងសៀវភៅដែលមានលើទីផ្សារទាំងអស់ (*លើកលែងតែសៀវភៅរឿងដើមរបស់គេ*)។

ក្រោយការប្រឹងសរសេរម្តងបន្តិចៗ ខ្ញុំក៏មានសៀវភៅមួយក្បាលហើយមួយក្បាលទៀត។ នេះជាកម្មសិទ្ធិរបស់ខ្ញុំ ហើយជាអ្វីដែលខ្ញុំត្រូវការពារ។ ខ្ញុំការពារអត្ថន័យនៅក្នុងសៀវភៅរបស់ខ្ញុំ បើសិនជាមានគេយល់ស្រប ឬពេបជ្រាយ។ ខ្ញុំ

ស្រលាញ់សៀវភៅរបស់ខ្ញុំ ដូច្នេះបើគេនិយាយប៉ះពាល់ ខ្ញុំនឹងចេញតតាំងភ្លាម។ ខ្ញុំប្រើសម្ដី មិនមែនទៅវាយគ្នាទេ ព្រោះទោះបីជាវាយក៏មិនឈ្នះគេដែរ។ អ្វីដែលគួរឱ្យឆ្ងល់នោះ គឺមនុស្សដែលមកថាឱ្យសៀវភៅរបស់ខ្ញុំ ច្រើនតែជាមនុស្សដែលមិនធ្លាប់សរសេរសៀវភៅដោយខ្លួនឯង។ ពួកនេះ មិនយល់ថាការសរសេរសៀវភៅពិបាកប៉ុណ្ណាទេ ព្រោះគេធ្លាប់អានពត៌មានបែកធ្លាយច្រើន រួចក៏គិតថា សៀវភៅក៏សរសេរដូចពត៌មានអត់

បានការទាំងនោះដែរ។

ចំពោះរបៀបការពារវិញ តែងផ្លាស់ប្ដូរជានិច្ច។ ជួនកាលខ្ញុំថាឱ្យគេខ្លាំង ជួនកាលខ្ញុំខ្ជិមមិនអាន Comment គេទៀតផង។ ខ្ញុំមានរបៀបសរសេររបស់ខ្ញុំ ដូច្នេះបើមិនពេញចិត្ត កុំអាន។ **ខ្ញុំអត់សរសេរដើម្បីទីផ្សារទេ ព្រោះបើសរសេរបែបនេះ ខ្ញុំមិនអាចបញ្ចេញយោបល់របស់ខ្ញុំបានទេ**។ ខ្ញុំមិនទទួលយកយោបល់កែតម្រូវទៀតទេ ព្រោះខ្ញុំធុញនឹងស្ដាប់ពាក្យរបស់អ្នកដទៃណាស់។ ពួកគេចង់ឱ្យខ្ញុំធ្វើឱ្យត្រូវចិត្តគេ។ ខ្ញុំជាអ្នកនិពន្ធ មិនមែនស្រីខាវ៉ាអូខេទេ ឱ្យផ្គាប់ចិត្តយ៉ាងម៉េច។ **អ្នកណាមិនចូលចិត្តក៏អត់ទៅ សំខាន់ខ្លួនខ្ញុំចូលចិត្តបានហើយ**។ ខ្ញុំមិនគិតពីអ្នកដទៃច្រើនពេក រហូតភ្លេចគិតពីខ្លួនឯងនោះទេ ព្រោះបើធ្វើបែបនេះ តើខ្ញុំធ្វើជាអ្នកនិពន្ធដើម្បីអី?

ខាងរោងពុម្ពដាំដើមជីវិត គេមិនឱ្យខ្ញុំសរសេររឿងនយោបាយ និងសាសនាទេ ព្រោះគេខ្លាចប៉ះពាល់ដល់ទីផ្សាររបស់គេ ដូច្នេះខ្ញុំត្រូវយកមកសរសេរក្នុងសៀវភៅណា ដែលខ្ញុំមិនផ្ញើរឱ្យគេ។ **ខ្ញុំចង់សរសេរអ្វីក៏បានដែរ ព្រោះខ្ញុំជាអ្នកនិពន្ធ**។ មិនមែន

ដោយសារតែកុងត្រាមួយសន្លឹក អាចបំបិទសិទ្ធិខ្ញុំបានទេ។ បើគេចង់ទុកខ្ញុំក៏ទុកទៅ បើមិនចង់ទេក៏តាមចិត្ត។ យ៉ាងច្រើនខ្ញុំអត់បានបោះពុម្ពសៀវភៅទៀតប៉ុណ្ណោះ។

កាលពីពាក់កណ្តាលឆ្នាំ២០១៦នេះ ខ្ញុំមានបញ្ហាតូចមួយនៅលើហ្វេសប៊ុក។ មាន page មួយបានយកសៀវភៅរបស់ខ្ញុំទៅចែកចាយដោយមិនប្រាប់មួយម៉ាត់ និងថែមទាំងយក logo ដ៏អាក្រក់មើលរបស់គេមកដាក់ពីលើគម្របសៀវភៅខ្ញុំទៀត។ សម្រាប់ខ្ញុំ ការយករបស់អាក្រក់បែបនេះមកដាក់លើគម្របសៀវភៅដែលខ្ញុំខំឌីហ្សាញ ប្រៀបដូចជាយកអាចម៍មកគប់ចំមុខខ្ញុំអ៊ីចឹង។ ខ្ញុំបានទាក់ទងទៅគេ ប៉ុន្តែគេមិនឆ្លើយតប។

ខ្ញុំទ្រាំលែងបាន ក៏ពឹងឱ្យអ្នកដែលស្គាល់ report ទៅហ្វេសប៊ុកដើម្បីឱ្យហ្វេសប៊ុកលុប post នោះចោល។ ក្រោយ report បានប៉ុន្មានថ្ងៃ ខាង Page នោះក៏តបមកខ្ញុំវិញដោយពាក្យសម្ដីអន់ជាងឆ្កែទៀត។ អ្នកទាំងអស់គ្នាយល់ហើយថា ហេតុអីបានជាអន់ជាងឆ្កែ? គឺគ្មានភាពស្មោះត្រង់។

គេនិយាយថា សៀវភៅរបស់ខ្ញុំ គេបានមកពីអ៊ីនធឺណេត ដូច្នេះគេគ្រាន់តែយកមកចែកចាយបន្តប៉ុណ្ណោះ។ ខ្ញុំឆ្ងល់ថា បើចែកចាយបន្ត ម៉េចចាំបាច់យក logo ខ្លួនឯងមកដាក់លើសៀវភៅខ្ញុំ។ សៀវភៅនេះ គ្មានចំណែក page នោះបន្តិចទេ ហើយខ្ញុំក៏មិនសរសេរដើម្បី page នោះដែរ។ គេថាខ្ញុំចិត្តចង្អៀត តែបើខ្ញុំចិត្តចង្អៀត តើខ្ញុំចែកសៀវភៅនោះនៅលើអ៊ីនធឺណេតធ្វើអី? ខ្ញុំគ្រាន់តែចង់ឱ្យមនុស្សដែលចូលចិត្តស៊ីពេរគេដូចពួកវា ចេះគោរពកម្មសិទ្ធិបញ្ញា និងសិទ្ធិអ្នកនិពន្ធខ្លះប៉ុណ្ណោះ។

Page នោះមានអ្នកគាំទ្រច្រើនណាស់ ព្រោះអីវាយកសៀវភៅ និងឯកសារជាច្រើនមក post ហើយសៀវភៅខ្លះ ត្រូវវាកែចំណងជើងទៀតផង។ អ្នកនិពន្ធផ្សេងទៀត មិនខ្វល់នឹងរឿងនេះទេ ព្រោះគេដឹងថាខ្មែរមានចរិតយ៉ាងម៉េច។ ប៉ុន្តែខ្ញុំមិនខ្វល់ទេ ចរិតយ៉ាងម៉េចក៏ដោយ ខ្ញុំនៅតែត្រូវការពារសៀវភៅរបស់ខ្ញុំដដែល។

ខ្ញុំហៅ page នោះថា page ចោរ និងអ្នកចែកចាយចំណេះដឹងអាចម៍ឆ្កែ ហើយខ្ញុំ បាន post screenshot ការសន្ទនារបស់ខ្ញុំជាមួយវានៅពេលយប់នៅលើហ្វេសប៊ុករបស់ខ្ញុំ។ ខ្ញុំចង់ឱ្យអ្នកគាំទ្រ page ចោរនោះបានទទួលពាក្យដូចគ្នាដែលខ្ញុំនិយាយទៅកាន់វា។ ខ្ញុំមិនថាឱ្យចំនោះទេ ព្រោះខ្ញុំគង់តែ unfriend គេចោលដដែល ដូច្នេះទុកមុខឱ្យគេខ្លះក៏ល្អដែរ។

ក្រោយមក ដល់កន្លែងសំខាន់ហើយ ជាកន្លែងដែលខ្ញុំត្រូវជ្រើសរើសថា ការពារ ឬបោះចោល។ មេរបស់ខ្ញុំ និងអ្នកធ្វើការជាមួយខ្ញុំ បានណែនាំខ្ញុំថា ឈប់រករឿងគេទៅ ព្រោះបើគេមិនឈប់ក៏យើងមិនដឹងធ្វើអីគេកើតដែរ។ ម្នាក់ទៀតនិយាយថា គេកំពុងធ្វើឱ្យយើងល្បីហើយ កុំទៅខ្វល់ពីគេ។ ខ្ញុំមិនស្តាប់ទេ ហើយក៏ស្តីឱ្យគាត់វិញ ព្រោះខ្ញុំត្រូវការការពារសៀវភៅរបស់ខ្ញុំ។

ការនិយាយដូចពួកគាត់ងាយណាស់ ព្រោះសៀវភៅមិនមែនជារបស់គាត់។ គាត់មិនដឹងថា ទម្រាំបានសៀវភៅមួយក្បាល ខ្ញុំត្រូវធ្វើអីខ្លះនោះទេ។ ខ្ញុំមិនមានខួរក្បាលឆ្លាតដូចពួកគាត់ទេ ដូច្នេះខ្ញុំត្រូវចំណាយពេលច្រើនណាស់ ទម្រាំដឹងថាត្រូវសរសេរអី។ ជួនកាល ខ្ញុំដឹងថាចង់សរសេរអីហើយ ប៉ុន្តែមិនដឹងថាត្រូវ

រៀបពាក្យយ៉ាងម៉េចទើបសម។ ខ្ញុំសរសេរសៀវភៅបាន ដោយសារខ្ញុំប្រឹងធ្វើវាប៉ុណ្ណោះ មិនមែនខ្ញុំឆ្លាតទេ ដូច្នេះខ្ញុំត្រូវតែការពាររបស់ខ្ញុំអ៊ីចឹង។

ឧទាហរណ៍ យើងមានកូនស្រីម្នាក់ ដែលយើងប្រឹងចិញ្ចឹមតាំងពីតូចមក។ ស្រាប់តែថ្ងៃមួយ ត្រូវគេចាប់រំលោភ ហើយត្រូវគេធ្វើឱ្យសម្រស់ទៀត។ យើងស្រែកឱ្យគេជួយ ស្រាប់តែគេប្រាប់យើង កុំស្រែកអី ព្រោះអ្នកដែលរំលោភកូនយើង កំពុងតែជួយកូនយើងល្បីតាមកាសែតហើយ។ ពីមុនមិនដែលមានអ្នកស្គាល់កូនយើងទេ ឥលូវនេះគេដឹងហើយថាកូនយើងត្រូវអ្នកណារំលោភ។ តើយើងនឹងមានអារម្មណ៍បែបណា? នេះជាអ្វីដែលកើតឡើងមកលើសៀវភៅរបស់ខ្ញុំ។ ខ្ញុំការពាររបស់ខ្លួនឯង ក៏ខុសដែរ។ មេខ្ញុំប្រាប់ថា ការប្រើពាក្យមិនល្អនៅលើអ៊ីនធឺណេត នឹងធ្វើឱ្យយើងក្លាយជាមនុស្សមិនល្អក្នុងភ្នែកអ្នកដទៃ។ សូមទោសផងមេ **ព្រោះភ្នែកអ្នកដទៃមិនមានតម្លៃក្នុងភ្នែកខ្ញុំទេ ហើយពាក្យរបស់មេឯង ក៏គ្មានតម្លៃស្មើសៀវភៅដែលខ្ញុំប្រឹងសរសេរដែរ។**

ទ្រឹស្តីអាចមិត្តែ(*មិនស្មោះត្រង់ និងកំសាក*) និងការណែនាំអត់បានការរបស់មេខ្ញុំ ជាអ្នកជម្រុញខ្ញុំឱ្យដាក់ពាក្យឈប់។ ខ្ញុំដាក់ពាក្យឈប់ ដើម្បីចេញពីមនុស្សដែលមិនគាំទ្រស្នាដៃរបស់ខ្ញុំ និងប្រាប់ឱ្យខ្ញុំបោះចោលស្នាដៃរបស់ខ្លួនឯង។ ខ្ញុំនឹងការពារសៀវភៅរបស់ខ្ញុំ ទោះបីជាគ្មានអ្នកណាជួយខ្ញុំក៏ដោយ។ **របស់យើង គឺយើងជាអ្នកការពារ។**

ឥលូវនេះ សៀវភៅដែលគេធ្លាប់លួចនោះ បានបោះពុម្ពលក់ហើយ តែខ្ញុំនៅតែមិនឈប់ការពារសៀវភៅទាំងនោះដដែល។ បើសិនជាខាងរោងពុម្ពធ្វើអីប៉ះពាល់សៀវភៅរបស់ខ្ញុំ ឬធ្វើឱ្យសៀវភៅរបស់ខ្ញុំទៅជាសៀវភៅបកប្រែដែរ ខ្ញុំនៅតែរករឿងគេដដែល។ បើគ្រាន់តែសៀវភៅខ្លួនឯង ក៏ខ្ញុំការពារមិនដដែល តើខ្ញុំទៅការពារអីបានទៀត?

ខ្ញុំការពារសៀវភៅរបស់ខ្ញុំ ដូចឆ្កែការពារឆ្អឹងដែលនៅក្នុងមាត់របស់វា ដូចការពារផ្ទះដែលវារស់នៅរាប់ឆ្នាំ និងដូចការពារកូនរបស់វាអ៊ីចឹង។ ខ្ញុំមានចរិតឆ្កែ ទោះមិនបាន១០០ភាគរយ ក៏បាន៧០ ទៅ៨០ភាគរយដែរ។ ចរិតឆ្កែនេះហើយ ដែលធ្វើឱ្យខុសពីអ្នកដែលនៅជុំវិញខ្លួនខ្ញុំ។ ពួកគេគិតថាចរិតឆ្កែជារឿងអាក្រក់ ដូច្នេះទើបគេបោះចោលអ្វីដែលពួកគេអាចការពារបានហើយទទួលយកអ្វីដែលពួកគេមិនចូលចិត្ត។

## ២-៥ ការពារខួរក្បាលរបស់ខ្ញុំ

ខ្ញុំធ្លាប់មើលពាណិជ្ជកម្មមួយនៅក្នុងទូរទស្សន៍ ដែលគេផ្សាយពីហ្វូមលាងមុខ។ គេប្រើពាក្យស្លោកថា *"ព្រោះយើងកើតមកមានមុខតែមួយ"* ដូច្នេះយើងត្រូវតែទិញផលិតផលគេយកមកប្រើទើបមុខយើងមិនជួបបញ្ហា។ ចំណុចសំខាន់នៅក្នុងការផ្សាយនេះ គឺការពារមុខដែលមានតែមួយ។ ខ្ញុំសួរខ្លួនឯងវិញ ចុះខួរក្បាល? ក្រែងយើងមានខួរក្បាលតែមួយដែរអី?

សម័យបច្ចេកវិទ្យា មនុស្សលែងចេះការពារខួរក្បាលរបស់ខ្លួនឯងហើយ។ ពួកគេឈប់ប្រើវាដើម្បីគិតវែកញែក តែបែរជាទុកវាចោលនៅក្នុងក្បាលទៅវិញ។ នេះមិនមែនជាមូលហេតុដែល

ធម្មជាតិ បង្កើតខួរក្បាលនៅក្នុងខ្លួនមនុស្សគ្រប់គ្នានោះទេ។ គ្រប់ផ្នែកនៃរាងកាយរបស់មនុស្ស មិនមែនមានដើម្បីតែល្អមើលទេ គឺមានតួនាទីរបស់វាច្បាស់លាស់។ បើយើងមិនដឹង វាមិនជាបញ្ហាធំទេ តែបើដឹងហើយ មិនយកមកប្រើ ទើបពិបាកនិយាយគ្នា។

តើយើងការពារខួរក្បាលរបស់យើងពីអ្វីខ្លះ?

ក្នុងចំណុចនេះ ខ្ញុំមិននិយាយពីផ្នែកពេទ្យទេ ព្រោះខ្ញុំគ្មានជំនាញ ហើយខ្ញុំក៏មានបញ្ហាក្នុងខួរក្បាលខ្ញុំដែរ។ ខ្ញុំនិយាយពីរឿងផ្សេងទៀត ដែលធ្វើឱ្យយើងបាត់បង់ម្ចាស់ការលើខួរក្បាលរបស់ខ្លួនឯង។ ខ្ញុំនិយាយពីការលាងខួរក្បាល ឬពង្វក់ខួរក្បាលដែលសម័យនេះកំពុងពេញនិយមខ្លាំងណាស់។

**បើយើងមិនចេះការពារទេ យើងនឹងត្រូវគេពង្វក់រហូតដល់ថ្ងៃស្លាប់មិនខាន**។ ចុះអ្នកណាជាអ្នកពង្វក់យើង? មានច្រើនណាស់ ដូចជា ៖ ប្រព័ន្ធផ្សព្វផ្សាយទាំងល្បី និងអត់ល្បី សាសនា ជំនឿផ្សេងៗ អ្នកនយោបាយ មុខជំនួញ សាលារៀន និងមនុស្សដែលនៅជុំវិញខ្លួនយើង។ ខ្ញុំនឹងនិយាយម្តងមួយថា គេពង្វក់ខួរក្បាលយើងយ៉ាងម៉េចខ្លះ។

ប្រព័ន្ធផ្សព្វផ្សាយ ជាកន្លែងដែលបញ្ចេញពត៌មានអត់បានការយ៉ាងច្រើន និងលាយចំណេះដឹងបន្តិចបន្តួចដែលយើងអាចរកបានតាមអ៊ីនធឺណេតយ៉ាងងាយបំផុត។ ប្រព័ន្ធផ្សព្វផ្សាយធំៗច្រើនតែជាដៃជើងរបស់អ្នកនយោបាយ ឬអ្នកជំនួញ ដូច្នេះគោលបំណងរបស់ពួកគេ គឺពង្វក់ខួរក្បាលមនុស្សហ្នឹងហើយ។ គេប្រើប្រព័ន្ធផ្សព្វផ្សាយ ក៏ព្រោះតែវាងាយស្រួលជាង និងបាន

ផលជាងពួកគេចុះទៅនិយាយដោយផ្ទាល់។ តាមពិតប្រព័ន្ធផ្សព្វផ្សាយ មិនមែនចូលភ្លាមមកពង្វក់ខួរក្បាលអ្នកមើលភ្លាមនោះទេ គឺគេពង្វក់អ្នកដែលធ្វើការក្នុងនោះសិន។ អ្នកទាំងនោះត្រូវគេប្រួដល់ជឿស៊ុបថា អ្វីដែលគេកំពុងធ្វើនេះ ជារឿងត្រឹមត្រូវ និងអស្ចារ្យ។ ហេតុនេះបានជាយើងឃើញអ្នកធ្វើការនៅក្នុងនោះមួយក្តាប់តូច មានចរិតអឿដូចព្រះដែរ។

**ប្រព័ន្ធផ្សព្វផ្សាយ ជាកន្លែងកើបលុយ ដែលចូលចិត្តធ្វើមិនដឹងមិនលឺពេលគេនិយាយរឿងលុយ។** គេច្រើនតែប្រើពាក្យវិជ្ជាជីវៈដើម្បីបោកចិត្តអ្នកមើល និងអ្នកស្តាប់ ឱ្យគិតថា "គ្មានបញ្ហាទេជឿគេទៅ"។ ពួកគេផ្សាយតែពត៌មានណាដែលគេចង់ឱ្យយើងដឹងប៉ុណ្ណោះ ចំពោះពត៌មានសម្ងាត់ គឺនៅតែសម្ងាត់ដដែល។

រាល់ព្រឹក ទូរទស្សន៍ និងវិទ្យុ ប្រណាំងគ្នាផ្សព្វផ្សាយពីគ្រោះថ្នាក់ចរាចរណ៍ និងការវាយតប់គ្នានៅកន្លែងផឹកស៊ី ទាំងខ្លួនឯងជួយផ្សាយពាណិជ្ជកម្មឱ្យក្រុមហ៊ុនស្រាបៀរ។ ពួកគេខំប្រឹងផ្សាយតែពត៌មានអវិជ្ជមាននៅពេលព្រឹក ដើម្បីធ្វើឱ្យអ្នកតាមដានមានការភ័យខ្លាច និងមិនសូវមានក្តីសង្ឃឹមក្នុងការរស់នៅ។ អ្វីដែលគេចង់បាន គឺ មនុស្សក្នុងប្រទេសទាំងអស់ ស្គាល់តែរឿងមិនល្អបានហើយ ដូច្នេះនៅពេលដែលអ្នកមានអំណាចគេធ្វើរឿងមិនល្អមកកាន់ប្រជាជន ពួកគេស៊ាំរួចជាស្រេច និងគ្មានការតវ៉ា។ គ្រាន់តែការចាក់បញ្ចូលរឿងអវិជ្ជមានទៅក្នុងខួរក្បាលមនុស្សហ្នឹង យើងក៏អាចសន្និដ្ឋានថា ប្រព័ន្ធផ្សព្វផ្សាយមានបំណងអាក្រក់មកលើខួរក្បាលយើងបាត់ទៅហើយ។

បើយើងគិតលើពាណិជ្ជកម្មដែលពួកគេបញ្ចេញមកវិញ យើងនឹងដឹងថា អ្វីដែលគេធ្វើ គឺមិនមែនសម្រាប់យើងទេ គឺសម្រាប់រកលុយប៉ុណ្ណោះ។ យើងកុំគិតថា គេឱ្យតម្លៃលើយើងច្រើនជាងលុយដែលរកបានទាំងដៃៗឱ្យសោះ។

ដោយសារតែប្រព័ន្ធផ្សព្វផ្សាយ និងការផ្សាយពាណិជ្ជកម្ម ជាប់ទាក់ទងគ្នា យើងសាកគិតពីពាណិជ្ជកម្មឱ្យហើយ។ រាល់ការផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ មានគោលបំណងពីរយ៉ាង គឺចង់បានអ្នកទិញភ្លាម និងចង់ឱ្យអ្នកទិញស្គាល់ផលិតផលរបស់ខ្លួន។ គោលបំណងទាំងពីរយ៉ាងនេះ គឺជាការពង្វក់ខួរក្បាលមនុស្ស។ គេព្យាយាមធ្វើយ៉ាងណាឱ្យមនុស្សក្រោយពេលមើលរួច ទប់តណ្ហាមិនជាប់ ហើយទៅរកទិញផលិតផលរបស់គេទោះបីមានលុយ ឬមិនមានក៏លែងជាបញ្ហាហើយ ព្រោះឥលូវនេះមានកម្ចី។ ក្រោយពេលខ្ចីហើយ មនុស្សនោះនឹងត្រូវធ្វើការច្រើនជាងមុន ដើម្បីដោះបំណុលទៅលើរបស់ដែលគេមិនត្រូវការសោះពីដំបូង។ **បើសិនជាយើងត្រូវការមែន មិនមែនទាល់តែមើលពាណិជ្ជកម្មរួច ទើបចង់ទិញនោះទេ។**

ការផ្សាយពាណិជ្ជកម្ម ជាវិធីសាស្ត្រមួយដើម្បីឱ្យមនុស្សច្រលំរវាងតម្រូវការ និងការចង់បាន។ ពេលដែលច្រលំហើយ មនុស្សនឹងប្រឹងទិញហើយទិញទៀត នៅតែមិនស្កប់ចិត្ត ព្រោះនោះមិនមែនជាតម្រូវការ។ **ចំពោះតម្រូវការវិញ ឱ្យតែបានហើយ គឺស្កប់ហើយ តែការចង់បានវិញ គ្មានដែនកំណត់ទេ។**

រាល់ពេលដែលខ្ញុំឃើញផ្សាយពាណិជ្ជកម្មទូរស័ព្ទថ្មី ខ្ញុំតែងតែមើលមក iPhone 5 របស់ខ្ញុំជានិច្ច ហើយគិតថា វានៅប្រើបាន

ហើយអត់មានបញ្ហាអ្វីទាំងអស់។ ខ្ញុំមិនត្រូវការទូរស័ព្ទថ្មីទេ ដូច្នេះខ្ញុំទុកលុយដើម្បីធ្វើអ្វីដែលត្រូវការវិញ ដូចជាទិញផ្ទះ ការប្រពន្ធ និងបើកហាងលក់សៀវភៅ។ ខ្ញុំមានតម្រូវការ ដូច្នេះខ្ញុំមិនភ្លើដកលុយទៅទិញ ដោយគ្រាន់តែមើលពាណិជ្ជកម្មប៉ុន្មាននាទីនោះទេ។ តាមពិតខួរក្បាលរបស់មនុស្សមានសមត្ថភាពគ្រប់គ្រាន់ដើម្បីទប់ស្កាត់អារម្មណ៍ចង់បានទាំងនេះ ប៉ុន្តែដោយសារតែយើងត្រូវគេពង្វក់ខួរក្បាលតាំងពីតូចមកហើយ ដូច្នេះវាមិនសូវខ្លាំងនោះទេ។

គោលបំណងទីពីរនៃការផ្សាយពាណិជ្ជកម្ម គឺឱ្យយើងស្គាល់។ យើងប្រហែលគិតថា គ្រាន់តែស្គាល់វាគ្មានទៅស្អីទេ។ ធ្លាប់ឃើញពស់លេបសត្វដទៃទេ គឺវារឹតឱ្យទន់ឆ្អឹងសិន ទើបលេបចូលតែម្តង។ ខួរក្បាលរបស់យើងនឹងត្រូវគេពង្វក់បន្តិចម្តងៗដូចតែគ្នាទេ។

អ្នកដែលមានអំណាចធំ គេមិនចង់ឱ្យប្រជាជនចេះខ្លាំងពេកទេ គេចង់ឱ្យយើងចេះល្មមត្រឹមតែគេអាចប្រើក្បាលបានប៉ុណ្ណោះ។ ដូច្នេះទើបគេបង្កើតប្រព័ន្ធផ្សព្វផ្សាយទាំងនេះឡើងមក។ គេដឹងថាមនុស្សជឿលើប្រព័ន្ធផ្សព្វផ្សាយ ដូច្នេះទើបគេចាត់ការខួរក្បាលយើងតាមវិធីនេះ។ **មនុស្សកាលណាខួរក្បាលលែងដំណើរការ នឹងត្រូវធ្វើតាមក្រឡាអុកដែលគេរៀបចំរហូត។** គេឱ្យទិញ ទិញ គេឱ្យសើច សើច តើដូចស្អីដែរ បើបែបនេះ?

ចប់មួយ ចូលដល់ ជំនឿ និងសាសនាម្តង។ រឿងក្តៅប្រចាំស្រុកយើង អ្នកណាប៉ះមិនបានទេ។ ឱ្យតែនិយាយអ្វីប៉ះពាល់ដល់សាសនា គេនឹងជេរស្តី ហើយប្រើហៅថា "**ទមិឡ**" ភ្លាម។ តើ

**ទមិឡ** មានន័យថាយ៉ាងម៉េច? ជាមនុស្សដែលមិនស្គាល់ល្អ អាក្រក់ ឬមនុស្សដែលមិនព្រមឱនក្បាលជឿលើសាសនា?

សេរីភាពជំនឿ នៅស្រុកយើងគ្មានទេ ព្រោះកើតមកភ្លាម ខាងភូមិឃុំ គេនឹងសរសេរក្នុងសំបុត្រកំណើតថា កាន់ព្រះពុទ្ធសាសនា ដោយមិនសួរយើងឡើយ។ ពេលធំឡើងបន្តិច ម៉ែឪ បងប្អូន នឹងខំប្រាប់យើងពីការទៅវត្ត និងរឿងរ៉ាវក្នុងធម៌ភ្លាម។ បើម៉ែឪខ្ញុំវិញ ចង់ឱ្យខ្ញុំទៅកោរសក់ទៀតផង។ កន្លែងណាដែលថាមានសេរីភាពក្នុងការរើសនោះ? អត់មានទេ។ កូនកើតមក ទាន់ពង្វក់ខួរក្បាលកូនខ្លួនឯងទៅហើយ។

សាសនា បំបិទផ្នែកមួយរបស់ខួរក្បាលមិនឱ្យធ្វើការ គឺការសួររកហេតុផល។ នៅក្នុងសាសនា មិនមានពាក្យសួររកហេតុផលទេ គឺមានតែពាក្យថាជឿប៉ុណ្ណោះ។ បើជឿចូលលុយមក។ កុំច្រឡំថាខ្ញុំនៅក្រុមជាមួយ LDP ឱ្យសោះ ព្រោះខ្ញុំមិនចូលចិត្តអ្នកនយោបាយដូចតែខ្ញុំមិនចូលចិត្តសាសនាអ៊ីចឹង។ តើអ្នកទាំងអស់គ្នាធ្លាប់ឆ្ងល់ទេ តើហេតុអីបានជាមនុស្សត្រូវការសាសនា? ធ្លាប់សួរទេ បើសិនជាគ្មានសាសនា តើនឹងមានរឿងអីកើតឡើង? សង្គ្រាម សម្លាប់ ឆក់ប្លន់ រំលោភបូក ដណ្តើមទ្រព្យគ្នា ? រឿងទាំងនេះកើតឡើងច្រើនណាស់ទៅហើយ នៅពេលដែលសាសនាកំពុងតែមាន។ ដូច្នេះតើសាសនាបានធ្វើអ្វីខ្លះ? ខ្ញុំមិនវាយប្រហារសាសនាទេ តែដោយសារខ្ញុំមិនចូលចិត្តសាសនា ទើបពាក្យដែលខ្ញុំសរសេរចេញមកដូចជាវាយប្រហារទៅលើសាសនា។

ខ្ញុំមានបទពិសោធន៍ច្រើនក្នុងរឿងនេះ ទម្រាំខ្ញុំសម្រេចថាបោះចោលសាសនា។ កាលខ្ញុំនៅរៀនអង់គ្លេស សាលាដែលខ្ញុំរៀននោះ គេបង្រៀនពីព្រះពុទ្ធសាសនា រាល់ថ្ងៃសុក្រ ព្រោះគេចង់យកសាសនាមកពង្វក់ខួរក្បាលសិស្សឱ្យជឿថា សាលារបស់គេល្អ។ ខ្ញុំមិនយកចិត្តទុកដាក់នឹងរឿងនោះទេ តែខ្ញុំក៏មិនបានទៅធ្វើអីឱ្យប៉ះពាល់គេដែរ។ គ្រូឱ្យសិស្សអង្គុយបិទភ្នែក តែខ្ញុំគ្មានអារម្មណ៍ធ្វើតាមទេ ព្រោះបើខ្ញុំយកលុយម៉ាក់ខ្ញុំមកបង់ដើម្បីបិទភ្នែកដដែល ខ្ញុំទៅដេកផ្ទះវិញក៏បានដែរ។ ម៉ាក់ខ្ញុំបើកធម្មទេសនាស្ដាប់រាល់ថ្ងៃ ល្អស្ដាប់ជាងពាក្យគ្រូក្មេងៗដែលទើបនឹងស្គាល់សាសនាទៀតផង។

ក្រោយមកគ្រូចាប់ផ្ដើមរករឿងខ្ញុំ និងបោះពាក្យថា "*បើសេងគៀងឯងមិនឱ្យ teacher ដឹកដៃដើរលើផ្លូវព្រះពុទ្ធសាសនាទេ teacherក៏មិនអាចជួយបានដែរ*"។ ខ្ញុំក៏ប្រលងធ្លាក់មែន។ គាត់មិនមែនមិនជួយខ្ញុំទេ គឺគាត់ជាអ្នករុញខ្ញុំ។ បើផ្លូវសាសនាដែលគាត់និយាយជាការបង្ខំបែបនេះ ខ្ញុំដើរលើផ្លូវរបស់ខ្ញុំវិញប្រហែលជាស្រួលចិត្តជាង។

សាសនានេះហើយ ដែលធ្វើឱ្យសិស្សក្នុងថ្នាក់មិននិយាយរកខ្ញុំ ហើយគេគិតថាខ្ញុំជាមនុស្សមិនល្អទៅវិញ។ បើគ្រាន់តែមិនគោរពសាសនា ក៏ក្លាយជាមនុស្សមិនល្អ ចុះលោកឧកញ៉ាធំៗ មន្ត្រីពុករលួយ និងអ្នកដែលនិយាយដើមគេនោះ ជាស្អីវិញ? វត្តក៏ពួកគេទៅ ព្រះក៏ធ្វើពីមាសយកមកពាក់ជាប់កទៀត ។ ហ្នឹងទើបហៅថាមនុស្សល្អ?

**សាសនាពង្វក់ខួរក្បាលមនុស្សឱ្យជឿថា មនុស្សដែលជឿសាសនាគ្មានកំហុស និងជាមនុស្សល្អទាំងអស់**។ ហេតុនេះ មនុស្សអាក្រក់ជាច្រើន ព្យាយាមទ្រទង់សាសនាកុំឱ្យដួល ដើម្បីមានរបាំងមុខដើម្បីពាក់ការពារខ្លួន។ ធ្វើខុសប៉ុនភ្នំ ហែរកឋិនចូលវត្តម្តង ក៏បានបុណ្យដែរ។ សម្រាប់មនុស្សអាក្រក់ធំៗ បានបុណ្យ គឺសម្ដៅទៅលើ មុខមាត់ លុយហូរចូលថែម និងគ្មានគេរករឿង។ គេមិនជឿលើបុណ្យដែលនិយាយក្នុងសាសនានោះទេ ព្រោះពួកគេដឹងថាអ្នកណាជាអ្នកបង្កើតសាសនា ហើយសាសនាបង្កើតធ្វើអី។ គេដឹងច្បាស់ជាងយើង ហេតុនេះ ទើបគេទុកសាសនានៅដដែល។

**កុំដោយសារតែមនុស្សភាគច្រើនជឿលើសាសនា ហើយយើងត្រូវបង្ខំខ្លួនឯងឱ្យចូលរួមនឹងគេ**។ ការធ្វើតាមគ្នា ឬគិតតាមគ្នា នេះហើយដែលបញ្ជាក់ថា ខួរក្បាលយើងត្រូវគេពង្វក់បាន។ **បើមានខួរ ត្រូវតែគិត ហើយកុំគិតដោយយកគំនិតអ្នកដទៃមកធ្វើជាគោល**។ គិតដោយខ្លួនឯង តើយើងត្រូវការសាសនាឬអត់? បើមិនត្រូវការ កុំខាតពេលជាមួយសាសនា។ បើសិនជាមាននរកអីមែន យើងមិនចុះនរកដោយសារតែរឿងនេះទេ កុំភ័យពេក។ យើងចុះនរកតែពេលយើងធ្វើអាក្រក់ប៉ុណ្ណោះ។ ការមិនជឿលើសាសនា ជារឿងធម្មតាទេ ព្រោះសាសនាកើតចេញពីគំនិតមនុស្ស។ យើងមិនជឿគំនិតអ្នកដទៃមកមិនតិចដែរហើយ ដូច្នេះថែមសាសនាមួយទៀត ក៏នៅតែមិនអីដែរ។

ចុះអ្នកនយោបាយវិញ? តើគេពង្វក់ខួរក្បាលយើងដោយវិធីណាដែរ? គឺពាក្យបោកប្រាស់ និងការតិះដៀលគ្នា។ បើសិនជាគេឱ្យខ្ញុំសរសេរពីអ្នកនយោបាយ ខ្ញុំនឹងសរសេរតែពីរចំណុច

នេះទេ ព្រោះវាត្រូវនឹងការពិតជាង។ អ្នកនយោបាយណាដែលមិនបោកប្រជាជនខ្លួនឯងនោះ? បើរាប់នៅស្រុកខ្មែរយើងវិញ គឺអត់មានតែម្ដង។ បោកហើយ ធ្វើឬកឡូយទៀត។ ប្រជាជននៅពេលត្រូវអ្នកនយោបាយបោកយូរទៅៗ ក៏លែងដឹងថាពាក្យណាពិត ឬកុហក។ ពាក្យដែលពិតរបស់អ្នកនយោបាយ គឺពាក្យដែលមិនជាប់រឿងនយោបាយ ចំណែកពាក្យកុហក គឺពាក្យដែលជាប់នឹងរឿងនយោបាយ។ នេះជារបៀបធ្វើនយោបាយក្នុងសម័យលុយជិះក្បាលមនុស្ស។

អ្នកនយោបាយ អាចនឹងនិយាយពាក្យពិត នៅពេលដែលតិះឌៀលដៃគូប្រជែងរបស់ខ្លួន តែគេមិននិយាយពីចំណុចអាក្រក់របស់ខ្លួនឯងទេ។ អ្នកនយោបាយ គិតថាខ្លួនឯងត្រូវតែល្អគ្រប់ដប់ ទើបប្រជាជនជឿ ដូច្នេះប្រឹងធ្វើយ៉ាងណាឱ្យដៃគូប្រជែងកាន់តែអាក្រក់ ដើម្បីខ្លួនឯងកាន់តែល្អ។ សម្រាប់ខ្ញុំ **អ្នកនយោបាយ គ្មានភាពជាអ្នកដឹកនាំស្អីបន្តិចទេ ព្រោះភាពជាអ្នកដឹកនាំ ត្រូវការភាពស្មោះត្រង់ជាមួយអ្នកនៅក្រោមបង្គាប់។**

មនុស្សជាច្រើន ត្រូវបានអ្នកនយោបាយកាន់កាប់ខួរក្បាល ហើយពួកគេក៏ទទួលចរិតដូចគ្នាបេះបិទ ពីអ្នកនយោបាយទាំងនោះ។ អ្វីដែលគួរឱ្យស្ដាយ គឺពួកគេមិនទទួលបានប្រយោជន៍អ្វីទាំងអស់ត្រលប់មកវិញ ក្រៅពីការខឹងសម្បារ និងភាពអាម៉ាសនៅពេលដែលដឹងការពិត។ អ្នកនយោបាយ និងការពិតមិនដើរផ្លូវរួមគ្នាតាំងពីដើមមកហើយ ដូច្នេះនៅពេលការពិតបង្ហាញខ្លួនអ្នកនយោបាយ និងលើកដៃបាយៗយើងមិនខាន។ រឿងដំបូងដែលគេពង្វក់មនុស្សគឺ យើងត្រូវតែចូលរួមជាមួយចលនានយោបាយរបស់ពួកគេ ព្រោះបើយើងមិនចូលទេ គេក៏មិនបាន

កាន់អំណាចដែរ។ គេនិយាយដូចជាការចូលរួមនេះជាអ្វីដែលប្រជាជនត្រូវតែធ្វើ ហើយគេឡៀលអ្នកដែលមិនចូលរួមថា មិនស្រលាញ់ជាតិ និងមិនស្គាល់តម្លៃជាពលរដ្ឋ។ តែបើយើងមើលឱ្យជ្រៅបន្តិច យើងនឹងឃើញថា គ្រប់សង្គ្រាម ការបំផ្លាញ ភាពរីករវរ ការលាបពណ៌ជនជាតិឯង ពុករលួយ កេងចំណេញលើប្រជាជន ទម្លាក់វប្បធម៌ជាតិ និងការយកសាសនាមកពង្វក់ប្រជាជនឯង គឺជាស្នាដៃរបស់អ្នកនយោបាយទាំងអស់។ **អ្នកនយោបាយទេ ដែលមិនស្រលាញ់ជាតិ ព្រោះបើពួកគេស្រលាញ់ជាតិ ពួកគេមិនប្រឆាំងគ្នាលិចកើតនោះទេ។ គេចង់បានអំណាចរៀងខ្លួនប៉ុណ្ណោះ។** អ្នកនយោបាយសាងមួយ បំផ្លាញវិញដប់ នេះជាន័យនៃការស្រលាញ់ជាតិរបស់ពួកគេ។

**ចំពោះតម្លៃរបស់ពលរដ្ឋវិញ ខ្ញុំគិតថា វាស្ថិតលើសេរីភាពក្នុងការរើស។** បើគេរើសមិនលូកដៃក្នុងការងារអត់បានការរបស់អ្នកនយោបាយ ក៏ជាសិទ្ធិរបស់គេ។ អ្នកនយោបាយគ្មានអ្វីត្រូវមកថាឱ្យប្រជាពលរដ្ឋទេ ព្រោះអ្នកនយោបាយគ្មានស្អីល្អផង ក្រៅពីមាត់ពូកែប្រូ។ បើចូលធ្វើនយោបាយគ្រប់គ្នា តើបានអ្នកណាទៅរកស៊ី បានអ្នកធ្វើឱ្យប្រទេសដើរទៅមុខ? អូ! ខ្ញុំភ្លេច គេមិនចង់ឱ្យយើងធ្វើនយោបាយទេ ព្រោះវាពិបាកចែកអំណាច បើមកច្រើនគ្នាពេក។ គេចង់បានយើងទៅធ្វើជាកូនអុកនយោបាយប៉ុណ្ណោះ។ ប្រើហើយ គ្រវាត់ចោល គ្មានអីពិបាក។

សម្រាប់ការអប់រំ ខ្ញុំមិនចាំបាច់និយាយទេ ព្រោះវាគ្មានបានការស្រាប់ទៅហើយ។ បើការអប់រំល្អ សម្ដេចមិនបញ្ជូនកូនចៅគាត់ទៅរៀនស្រុកក្រៅទេ ហើយសាលាធំៗក៏មិនទទួលអ្នកដែលមានសញ្ញាបត្រពីបរទេសដែរ។ សូម្បីតែអ្នកដែលនៅក្នុង

ស្ថាប័នអប់រំ ក៏គ្មានទំនុកចិត្តលើការអប់រំរបស់ខ្លួនឯងផង តែកុំឱ្យមានគេទៅសម្ភាស ចាំមើលគេនិយាយធ្វើឡូយ។

ការអប់រំ ពង្វក់ខួរក្បាលក្មេងកុំឱ្យគិត។ ចេះតែថាតាមគេ និងធ្វើតាមគេប្រាប់ក្នុងសៀវភៅបានហើយ។ ចំពោះការរឹតបន្តឹងពេលប្រឡងសម្រាប់សិស្សវិទ្យាល័យវិញ ខ្ញុំគិតថាគ្មានប្រយោជន៍ទេ ព្រោះមុខវិជ្ជាដែលរៀននោះប្រើមិនបានផលទេ ពេលចេញមកធ្វើការ លើកលែងតែសិស្សនោះទៅធ្វើជាគ្រូបង្រៀន។ បង្រៀនឱ្យសិស្សចេះគិត និងស្អប់ការទ្រពងក្នុងសង្គមទៅ គឺគ្រប់គ្រាន់នឹងផ្លាស់ប្តូរផ្នែកធំៗបានហើយ។ ធ្វើតាមតែក្រសួង ខ្លាចធ្លាក់ដល់ពេលធំឡើង ធ្វើតាមតែមេ វាយអាណាក៏បាន ឱ្យតែមេឱ្យទៅ។ គិតទៅគេពង្វក់យើងទាំងយើងមិនដឹងខ្លួន។

ខ្ញុំផ្អាកត្រឹមនេះហើយ ព្រោះខ្ញុំគិតថាអ្នកទាំងអស់គ្នាអាចយល់បានពីការពង្វក់ខួរក្បាលហើយ។ ដូច្នេះយើងត្រូវដឹងពីវិធីការពារវិញម្តង។ យើងត្រូវការពារខួរក្បាលយើងឱ្យដូចឆ្កែការពារផ្ទះរបស់វា។

វិធីដោះស្រាយគឺ ការរៀនដោយខ្លួនឯង។ យើងត្រូវអានឱ្យបានច្រើន និងឱ្យបានជ្រៅ។ ពេលអានត្រូវចេះមានសំនួរ ព្រោះជួនកាលសៀវភៅក៏មិនអាចប្រាប់ការពិតអស់ដែរ។ អ្វីដែលយើងចង់ដឹង ត្រូវតែទៅស្រាវជ្រាវដោយខ្លួនឯង។ បើយើងចាំអ្នកដទៃស្រាវជ្រាវហើយ រៀបចំយ៉ាងស្អាតមកឱ្យយើង គេនឹងពង្វក់ខួរក្បាលយើងមិនខាន។ **អ្នកដែលត្រូវគេពង្វក់ភាគច្រើនជាមនុស្សខ្ជិល**។ កុំខ្ជិល កុំពឹងគេ កុំឱ្យគេពង្វក់ខួរក្បាលយើង។

ការពារឱ្យបាន ព្រោះខួរក្បាលនៅក្នុងខ្លួនយើងទេ បើគេយកបានទៀត ចប់ហើយ។

## ២-៦ ការពារប្រទេសរបស់ខ្លួន

**យើងកើតនៅប្រទេសណា យើងមានតួនាទីការពារប្រទេសនោះ។** ទ្រឹស្តីនេះប្រើមិនបានផលជាមួយជនជាតិយួនទេ ព្រោះយួនទោះកើតលើទឹកដីណា ក៏នៅតែគិតពីប្រយោជន៍ប្រទេសយួនរបស់គេដែរ។

ខ្ញុំគិតថា ខ្ញុំបានជួយការពារប្រទេសរបស់ខ្ញុំដែរ ដោយខ្ញុំបានសរសេរសៀវភៅជាភាសាខ្មែរ។ នេះជាកិច្ចការដែលខ្ញុំអាចធ្វើបានដើម្បីប្រទេសនេះ។ ខ្ញុំដឹងថា ប្រជាជនខ្មែរមិនចូលចិត្តអានសៀវភៅទេ តែចូលចិត្តអានពត៌មានបែកធ្លាយ និងពត៌មានអត់បានការ។ ប៉ុន្តែបើខ្ញុំទៅសរសេរពត៌មានបែបនេះដែរ ដើម្បីឱ្យមានគេអានស្នាដៃរបស់ខ្ញុំ តើខ្ញុំអាចធ្វើអ្វីខ្លះឱ្យប្រទេសនេះ។ ដូច្នេះការសរសេរសៀវភៅ ជាជម្រើសល្អបំផុត និងល្ងង់បំផុតដែលខ្ញុំរើសយក។

ខ្ញុំចងក្រងឯកសារជាភាសាជាតិ ដើម្បីឱ្យអ្នកដែលចូលចិត្តអានភាសាជាតិបានអាន និងបានដឹងថាមានអ្វីកើតឡើងខ្លះ។ ទោះបីខ្ញុំសរសេរពីខ្លួនក៏ដោយ តែតាមរយៈសំណេររបស់ខ្ញុំ អ្នកអានអាចដឹងថា សង្គមដើរដល់ណាហើយ។ ខ្ញុំមិនដូចអ្នកនិពន្ធខ្លះទេ បកប្រែតែសៀវភៅបរទេស ហើយហ៊ានហៅខ្លួនឯងថាជាអ្នកនិពន្ធដែរ។ ខ្ញុំនិយាយត្រង់បន្តិចហើយ ព្រោះការបកប្រែសៀវភៅពីបរទេសនេះ ល្អសម្រាប់អ្នកអាន ព្រោះគេអាចសន្សំលុយបានច្រើន បើប្រៀបនឹងការទិញសៀវភៅបរទេស។ ប៉ុន្តែ

ការធ្វើបែបនេះ ជាការមើលងាយដល់អ្នកនិពន្ធក្នុងស្រុក និងបំបាក់ទឹកចិត្តរបស់អ្នកដែលចង់សរសេរក្រោយទៀត។

ខ្ញុំធ្លាប់បាននិយាយជាម្ចាស់រោងពុម្ព **ប្រាជ្ញ វិជ័យ** អំពីរឿងនេះ។ គាត់ថាមិនអាចបោះចោលការបកប្រែបានទេ ព្រោះនេះជាប្រភពចំណូល។ គាត់ជាអ្នករកស៊ី ចង់និយាយម៉េចក៏បានដែរ តែខ្ញុំជាអ្នកនិពន្ធ ខ្ញុំមិនគិតដូចគាត់ទេ។ ខ្ញុំចង់ឱ្យមានអ្វីដែលជារបស់ជាតិឯង មិនមែនបកប្រែពីគេមក ហើយលួចកែន័យតិចតួច ក៏ដាក់ពីលើក្របថា ជាស្នាដៃកូនខ្មែរទេ។ ខ្ញុំខ្មាសខ្លួនឯង ទោះបីបរទេសគេមិនដឹង ក៏ខ្ញុំនៅតែខ្មាសខ្លួនឯងដែរ។ ខ្ញុំទទួលស្គាល់ថា ទឹកដៃសរសេរ និងចំណេះដឹងរបស់ខ្ញុំ មិនស្មើនឹងអ្នកនិពន្ធបរទេស ប៉ុន្តែចិត្តស្រលាញ់ការសរសេរសៀវភៅរបស់ខ្ញុំ មិនតូចជាងគេទេ។ ខ្ញុំសរសេរទោះបីគ្មានអ្នកណាអាន ឬគ្មានអ្នកណាឱ្យតម្លៃ។

**ខ្ញុំជាអ្នកនិពន្ធ ដូច្នេះភាសាជាតិ ជាផ្នែកមួយរបស់ជាតិដែលខ្ញុំត្រូវការពារ**។ សម្រាប់អ្នកទាំងអស់គ្នា ខ្ញុំមិនដឹងថាធ្វើការអីទេ ដូច្នេះសួរខ្លួនឯងទៅ តើផ្នែកណាមួយដែលយើងត្រូវការពារ? យើងមិនអាចការពារប្រទេសទាំងមូលបានទេ ដោយសារតែប្រទេសទាំងមូល មិនមែនមានតែយើង។ កុំទម្លាប់មានចរិតតួឯកបែបនេះ ព្រោះនេះជាលេសដែលអ្នកនយោបាយយកមកបោករាស្ត្រ។ ពួកគេនិយាយថា គេអាចការពារប្រទេសទាំងមូលបាន។ ការពារស្អី? សមាគមន៍អ្នកនិពន្ធខ្មែរ បិទទ្វារគ្មានអើពើផង។ ពួកគេចង់ប្តូរភាសាទេដឹង?

ខ្ញុំការពារប្រទេសរបស់ខ្ញុំ តាមសមត្ថភាពដែលខ្ញុំមាន មិនទៅដេកស្រមៃជាមួយមនុស្សដែលបានតែស្រែកទេ។ បើថ្ងៃក្រោយ ខ្ញុំដឹងច្រើនពីវប្បធម៌ និងប្រវត្តិអ្វីផ្សេងទៀត ខ្ញុំនឹងសរសេរជាសៀវភៅទាំងអស់ដើម្បីទុកជាឯកសារ។ អ្វីដែលខ្ញុំប្តេជ្ញាចិត្តមួយទៀត គឺសរសេរឱ្យល្អ និងច្បាស់ៗ។

មិនមែនទាល់តែធ្វើប៉ូលីស ឬធ្វើទាហានទើបអាចការពារប្រទេសបាននោះទេ។ ប៉ូលីសខ្លះធ្វើដើម្បីលុយប៉ុណ្ណោះ ហើយទាហានខ្លះធ្វើដើម្បីមានអំណាចមកដណ្តឹងកូនគេជិតផ្ទះទេ។ មិនមែនថាអត់មានប៉ូលីសល្អ និងទាហានដែលស្មោះត្រង់នោះទេ ប៉ុន្តែភាគច្រើនគឺបែបនេះឯង។ ប៉ូលីស និងទាហាន មិនប្រាកដថាបានទៅការពារប្រទេសទេ ព្រោះអ្នកនយោបាយមានការងារច្រើនពេក ត្រូវការពួកគាត់គ្រប់ពេល។

បើអ្នកទាំងអស់គ្នាមិនបានការពារប្រទេសខ្លួនទេ និយាយប្រាប់ខ្លួនឯងផងថា "**អញអន់ជាឆ្កែទៀត**"។

## ២-៧ មិត្តភក្តិខ្ញុំ និងក្បាច់គុន

ខ្ញុំមានមិត្តភក្តិម្នាក់ ឈ្មោះសម្បត្តិ ជាគ្រូបង្ហាត់នៅក្នុងសហព័ន្ធយុទ្ធក្រមខម ដែលទើបនឹងត្រូវគេដាក់ទៅបង្ហាត់កងទ័ព។ តែឥលូវគាត់ផ្អាកហើយ ព្រោះមានការផ្លាស់ខ្លួន។ ខ្ញុំក៏ធ្លាប់មើលវីដេអូដែលគេហាត់នៅតាមសាលាដែរ តែខ្ញុំខ្លាចឈឺ ទើបគ្មានចំណាប់អារម្មណ៍ចូលហាត់។

កាលពីមុនសរសេរសៀវភៅនេះ ខ្ញុំបាននិយាយជាមួយសម្បត្តិពីរឿងក្បាច់គុន ព្រោះខ្ញុំទើបមើលការប្រកួត UFC រួច។ ខ្ញុំចង់

ដឹងថាក្បាច់គុនខ្មែរយើង បើចូលវាយជាមួយគេអាចយ៉ាងម៉េចដែរ។ និយាយដល់ក្បាច់គុន ទើបសម្បត្តិប្រាប់ខ្ញុំថា "**ក្បាច់គុនបានន័យថា ការប្រយុទ្ធដោយប្រើអាវុធ**"។

ខ្ញុំដកស្រង់ការពន្យល់ខ្លះរបស់មិត្តភក្តិខ្ញុំឱ្យបានដឹង។

*"ល្បុក្កតោគឺជាឈ្មោះអាវុធមួយ ដូច្នេះគេហៅថាក្បាច់គុនល្បុក្កតោ គឺប្រយុទ្ធដោយប្រើល្បុក្កតោ។ យុទ្ធក្រមខម ជាក្បួនចម្បាំងរបស់ខ្មែរដើម ដែលមានទាំងប្រើអាវុធនិងអត់ប្រើអាវុធ។*

*បើប្រយុទ្ធដោយដៃទទេ ជាអត្តយុទ្ធ មិនអាចហៅថាក្បាច់គុនទេ។ ពាក្យគុន គឺសំដៅតែលើអាវុធប៉ុណ្ណោះ ដូចជា ដាវ ដំបង ខែង ធ្នូ លំពែង កាំបិយ កាំបិត និងមានច្រើនទៀត។ ការប្រដាល់រាល់ថ្ងៃ មិនប្រើក្បាច់គុនទេ តែប្រើអត្តយុទ្ធ។ ចំណែក MMA គឺ អត្តយុទ្ធចម្រុះ គឺយកក្បាច់អត្តយុទ្ធរបស់ប្រទេសជាច្រើនមកប្រើរួមគ្នា។ អត្តយុទ្ធរបស់ខ្មែរ ស្ទើរតែស្មើនឹង MMA ទៅហើយ ព្រោះមានក្បាច់ច្រើន និងមានក្លេទៀត។*

*ពាក្យថាអត្តយុទ្ធ មានន័យថាការប្រយុទ្ធដោយប្រើខ្លួនផ្ទាល់ គឺដៃ កែង ជង្គង់ ជើង ចំបាប់ ក្លេ ក្បាលបុក ស្មាបុក គូទ គឺប្រើគ្រប់ផ្នែកនៃរាយកាយ ដែលអាចប្រើបានយកមកវាយ ឬរង*"។

ខ្ញុំដកយកពាក្យទាំងស្រុងរបស់សម្បត្តិ ដោយមិនមានកែប្រែទេ គ្រាន់តែខ្ញុំលុបចោលកន្លែងខ្លះដែលជេរគ្នាលេងប៉ុណ្ណោះ។ ពួកខ្ញុំជាមិត្តភក្តិ ដូច្នេះទោះបីសួររឿងសាច់ការ ក៏ត្រូវតែមានកន្លែងអត់បានការលាយឡំដែរ។ ប៉ុន្តែទិន្នន័យទាំងនេះអាចឱ្យយើងដឹងថា អ្វីដែលយើងលឺចេញពីមាត់ពិធីករតាមទូរទស្សន៍ថា

"ក្បាច់គុន" នោះជាពាក្យដែលប្រើខុស។ ពាក្យត្រឹមត្រូវគឺ "អត្តយុទ្ធ"។

សម្បត្តិ ដឹងពីរឿងទាំងនេះដោយសារបានហាត់ដោយខ្លួនឯងផង និងស្រាវជ្រាវបន្ថែមផង។ មិត្តភក្តិខ្ញុំក៏ចេះការពារខួរក្បាលខ្លួនឯងដែរ ដោយមិនចាំគេមកប្រាប់។

## ២-៨ អ្នកលួច ចាំតែលួច

អ្នកថា ចាំតែថា អ្នកធ្វើ ចាំតែធ្វើ ហើយអ្នកលួច ចាំតែលួច។ ដូច្នេះតើយើងដែលជាម្ចាស់កម្មសិទ្ធិនេះ ចាំត្រូវតែគេលួចគ្រប់ពេលឬ? តើយើងមិនចេះការពាររបស់ខ្លួនឯងទេ?

សម្បត្តិធ្លាប់បានប្រាប់ខ្ញុំថា ថៃនៅតែចង់បានក្បាច់គុនពីខ្មែរបន្ថែមទៀត ដើម្បីពង្រីកវិស័យក្បាច់គុនរបស់គេ។ នៅថៃ មានអ្នកចេះដឹងពីក្បាច់គុនច្រើន ដូច្នេះបើគេបានស្នៀតថ្មីៗពីខ្មែរយើងទៅទៀត គេនឹងអាចបំបែកស្នៀតទាំងនោះបានកាន់តែច្រើន ហើយចុងក្រោយ យើងនឹងមិនអាចប្រៀបជាមួយថៃបានទេក្នុងផ្នែកនេះ។

ថៃលួចដោយបើកចំហរក្នុងរបៀបទិញដូរ ប៉ុន្តែសំណាងហើយដែលខាងយុទ្ធក្រមខមគេមិនព្រមនោះ។ បើយើងដឹងថានេះជារបស់យើង យើងត្រូវតែការពារ។

## ២-៩ ផ្នែកមួយនៃភាពជាអ្នកដឹកនាំ

ខ្ញុំមិនចូលចិត្តដឹកនាំអ្នកដទៃទេ ព្រោះខ្ញុំមិនចង់ពិបាកខ្លួនឯង។ ប៉ុន្តែការចេះការពាររបស់ខ្លួន គឺផ្នែកមួយនៃភាពជាអ្នកដឹកនាំ។

អ្នកដឹកនាំដែលមិនចេះការពារសមិទ្ធិផលរបស់ខ្លួនឯង កូនចៅ ឬឱកាសរីកចម្រើនរបស់ខ្លួនឯង មិនសមធ្វើជាអ្នកដឹកនាំទេ។

អ្នកដឹកនាំត្រូវដឹងពីវិធីវាយចូល និងការពាររបស់ខ្លួន។ បើសិនជាប្រធានក្រុមហ៊ុនម្នាក់ដឹងតែពីវិធីបញ្ចេញផលិតផលទៅលើទីផ្សារ តែមិនចេះការពារទឹកចិត្តរបស់បុគ្គលិករបស់ខ្លួន មុននឹងក្រោយគេនឹងបាត់បង់បុគ្គលិកល្អៗអស់មិនខាន។ មនុស្សល្អមិនទ្រាំធ្វើការជាមួយមេដែលមិនចេះការពារពួកគេនោះទេ។

សម្រាប់អ្នកដែលមានបំណងប្រាថ្នាចង់ធ្វើជាអ្នកដឹកនាំ កុំភ្លេចពីចំណុចនេះផង។ **ការពារអ្វីដែលយើងមានឱ្យបាន។** ខ្ញុំចង់ធ្វើជាអ្នកនិពន្ធសៀវភៅប៉ុណ្ណោះ សម្រាប់ការដឹកនាំ ទុកឱ្យមនុស្សដែលឃ្លានដើរមុខគេធ្វើទៅ។ ខ្ញុំនិយាយលេងទេ អ្នកណាក៏អាចធ្វើជាអ្នកដឹកនាំបានដែរ។ អ្នកខ្លះល្អ អ្នកខ្លះអាក្រក់ តែអ្នកដឹកនាំ នៅតែមានទីផ្សារជានិច្ច។

## ២-១០ រឿងខ្លី

បុរសម្នាក់បានទៅលេងស្គីទឹកកក នៅលើភ្នំមួយជាមួយនឹងឆ្កែរបស់គេ។ ឆ្កែនេះស្រលាញ់ម្ចាស់វាណាស់ ដូច្នេះទើបម្ចាស់វានាំវាមកលេងនៅលើភ្នំនេះដែរ។ រាល់ពេលដែលម្ចាស់វាជិះស្គីលេង វាតែងតែរត់តាមពីក្រោយជានិច្ច។ បុរសនេះមិនសូវជាមានជំនាញក្នុងការជិះប៉ុន្មានទេ ប៉ុន្តែគេចូលចិត្ត។

នៅថ្ងៃនោះ បុរសនោះបានជិះស្គីលឿនពេកក៏ជ្រុលធ្លាក់ចេញពីជ្រោះមកខាងក្រោម។ ឆ្កែនោះឃើញដូច្នេះក៏រត់ចុះទៅតាមមើលនៅខាងក្រោម។

បុរសនោះបានស្លាប់បាត់ទៅហើយ ដោយបោកក្បាលនឹងផ្ទាំងថ្ម។ ឆ្កែបានយកច្រមុះរបស់ទៅឆ្កឹះមុខម្ចាស់វា ក្នុងគោលបំណងដើម្បីដាស់ឱ្យភ្ញាក់។ ឆ្កែនោះមិនចេញទៅណាពីម្ចាស់វាទេ ដោយវានៅដេកក្បែរខ្លួនម្ចាស់វាជដែល។

បីថ្ងៃក្រោយ ទើបមានក្រុមសង្គ្រោះចុះមកដល់ទីនោះ ក្រោយមានការប្ដឹងរករបស់ក្រុមគ្រួសារ។ សពនោះឡើងរឹងកកដោយសារតែអាកាសធាតុត្រជាក់ពេក។ ចំណែកឆ្កែនោះក៏ស្ទើរតែដួលដែរ ព្រោះវាគ្មានអីស៊ី ហើយរងារដែរ។ ឆ្កែពេលដែលឃើញគ្រួសាររបស់វាមកដល់ វាក៏រត់ទៅទទួល។ ក្រុមសង្គ្រោះបានយកសពបុរសនោះចេញទៅ ហើយឪពុកបុរសនោះក៏បានបីឆ្កែចេញទៅដែរ។

*នេះជារឿងពិតមួយដែលខ្ញុំអាននៅក្នុងពត៌មានបរទេស។ ឆ្កែនោះនៅការពារខ្មោចម្ចាស់វា រហូតដល់មានគេមកជួយ។*

# ចរិតទី៣

## បើខាំមិនឈ្នះ មិនខាំតែម្ដង

កាលខ្ញុំនៅធ្វើការក្នុងក្រុមហ៊ុនចាស់ ខ្ញុំបានមើលវីដេអូមួយដែលគេថតឆ្កែបីក្បាលកំពុងតែខាំគ្នា។ ឆ្កែពីរ ខាំឆ្កែមួយទៀតដោយមិនឱ្យវារត់រួច។ ដល់មួយសន្ទុះធំ ទើបមានគេបំបែកវាចេញបាន។ ឆ្កែមួយដែលទ្រោមជាងគេនោះ ក៏រត់ចេញយ៉ាងលឿន តែបើតាមខ្ញុំគិត ប្រហែលជាមិនរស់ទេ ព្រោះឈាមហូរច្រើនណាស់។

វីដេអូនេះ ធ្វើឱ្យខ្ញុំនឹកឃើញដល់កូនឆ្កែរបស់មិត្តភក្តិខ្ញុំនៅក្រចេះ ដែលត្រូវឆ្កែធំៗខាំ។ គេប្រាប់ថា មានឆ្កែអ្នកជិតខាងបីក្បាលបានមកដេញខាំកូនឆ្កែនោះដល់មុខផ្ទះ។ ម្ចាស់ផ្ទះបានយកដំបងទៅវាយវាដែរ តែដោយសារឆ្កែទាំងនោះធំៗពេកដូច្នេះពិបាកដេញវា។ ទម្រាំតែដេញបាន កូនឆ្កែនោះដេកស្ងៀមបាត់ទៅហើយ។ វាមិនទាន់ងាប់ទេ តែវាជិតងាប់។ ពេលខ្ញុំឡើងដេកពេលយប់ ខ្ញុំលឺវាស្រែក ព្រោះមេឃត្រជាក់ដូច្នេះរបួសវាកាន់តែឈឺខ្លាំង។

ឆ្កែ គឺបែបនេះ។ វាមិនខាំគ្នាលេងទេ លើកលែងតែជាមួយម្ចាស់វា ឬគ្នាវា។ តែបើជាមួយឆ្កែផ្សេង គឺខាំទាល់តែងាប់ បើគ្មានមនុស្សចូលទៅបំបែក។ យើងអាចគិតថា សាហាវបន្តិច ប៉ុន្តែនេះជាចរិតមួយល្អដែរ។ **បើសិនជាខាំមិនឈ្នះ ឬខាំមិនងាប់ទេ គឺមិនចូលខាំតែម្ដង**។ តើហេតុអីត្រូវខាតពេលទៅខាំ បើយើង

គ្មានបំណង ឬគ្មានវិធីយកឈ្នះផងហ្នឹង? **ខាំដើម្បីល្បីឈ្មោះ ឬខាំឱ្យគេហៅ មិនមែនជាចរិតឆ្កែទេ តែជាចរិតមនុស្ស។**

## ៣-១ តើអ្នកណាអាចជៀសផុតពីជម្លោះបាន?

ចម្លើយខ្លី គឺអត់មានទេ។ សិស្សក៏មានជម្លោះ គ្រូបង្រៀនក៏មានជម្លោះ អ្នកធំក៏មានជម្លោះ អ្នកតូចតាចក៏មានជម្លោះ។ **ជម្លោះជាការបញ្ជាក់ថា មនុស្សកើតមកមានភាពខុសគ្នាពីកំណើត គ្រាន់តែភាពខុសគ្នានេះ មិនទាន់ប៉ះទង្គិចគ្នាប៉ុណ្ណោះ។** ថ្ងៃនេះយើងអាចនឹងមិនមានជម្លោះជាមួយអ្នកជិតខាងយើងទេ តែថ្ងៃក្រោយមិនប្រាកដទេ។ វាអាចយើងទៅរករឿងគេមុន ឬគេមកបង្ករឿងមុនក៏ថាបាន។ **ជម្លោះ ជារឿងដែលស្មានមិនដឹង ហេតុនេះទើបយើងជៀសមិនផុតគ្រប់គ្នា។**

បើយើងដឹងថា ជម្លោះ គឺជៀសមិនផុតទៅហើយ យើងត្រូវតែចេះត្រៀមខ្លួនឱ្យបានមុន។ នេះមិនមែនបានន័យថា យើងត្រៀមខ្លួនទៅឈ្លោះជាមួយគេគ្រប់ពេលនោះទេ។ យើងត្រៀមខ្លួន ដើម្បីកុំឱ្យចូលទៅក្នុងជម្លោះដោយមិនគិត ព្រោះការចូលបែបនេះ មិនអាចបានអ្វីមកវិញទេ។

**ជម្លោះតូច ឬធំ ក្រោយពេលដល់ទីបញ្ចប់ វានឹងក្លាយជាមេរៀនមួយដូចគ្នា។** បើយើងមិនចេះចាំ ជម្លោះដដែលនេះនឹងកើតឡើងម្តងទៀត។ គូសង្សារជាច្រើន ឈ្លោះគ្នានឹងរឿងដដែលៗ ព្រោះតែមិនចេះចាំ ហើយគិតថា មិនអាចមានជម្លោះម្តងទៀតទេ។ ការគិតបែបនេះ ខុសទាំងស្រុង ព្រោះគ្មានអ្នកណាទាយដឹងមុនពីជម្លោះទេ។ ជម្លោះកើតឡើងងាយណាស់ តែមិន

បញ្ចប់ដោយងាយទេ។ ជម្លោះពីរឿងតូចមួយ អាចធ្វើឱ្យមនុស្ស ខាតបង់ពេលយ៉ាងយូរ។

**បើសិនជាគេចមិនកើតទេ កុំគេច ត្រូវងាកមកប្រឈមមុខម្តង។**

## ៣-២ តើពេលណាដែលត្រូវប្រឈមមុខ?

សំណួរនេះ ត្រូវតែសួរនៅពេលចាប់ផ្តើមមានជម្លោះភ្លាម។ យើងត្រូវដឹងថា តើពេលនេះយើងត្រូវប្រឈមមុខ ឬដើរចេញ។ បើយើងមិនច្បាស់ថាពេលណាជាពេលសមគួរនឹងចេញទៅតទល់ទេ យើងនឹងមិនអាចឈ្នះគេបានទេ។ ក្បួនសឹកស៊ុនជឺបាននិយាយថា "**អ្នកដែលឈ្នះ គេដឹងថាឈ្នះតាំងពីមិនទាន់ចូលច្បាំងម្ល៉េះ ហើយអ្នកដែលចាញ់ចូលដល់សមរភូមិហើយទើបរកវិធីយកឈ្នះ**"។ ដឹងមុន មិនមែនជារឿងអាក្រក់ទេ។

ដូច្នេះ តើពេលណាដែលយើងត្រូវប្រឈមមុខខ្លះ? ចម្លើយនេះខុសគ្នាទៅតាមមនុស្សប្រភេទផ្សេងគ្នា។ ខ្ញុំនឹងឱ្យចម្លើយរបស់ខ្ញុំទៅអ្នកទាំងអស់គ្នា ហើយអ្នកទាំងអស់គ្នាត្រូវគិតពីចម្លើយរបស់ខ្លួនឯង។

ខ្ញុំនឹងប្រឈមមុខ បើសិនជា ៖

- ខ្ញុំមានសង្ឃឹមឈ្នះច្រើនជាង ឬឈ្នះគ្រប់ចំណុច។ បើសិនជាក្នុងជម្លោះ ខ្ញុំជាភាគីត្រូវ ខ្ញុំនឹងប្រឈមមុខព្រោះខ្ញុំអាចមានប្រៀបជាង។ លើកលែងតែខ្ញុំទៅមានរឿងជាមួយអស់លោកអ្នកធំដែលចូលចិត្តធ្វើបានអ្នកទន់ខ្សោយ ទើបខ្ញុំត្រូវគិតឡើងវិញ។ សង្ឃឹមឈ្នះច្រើន

ឬតិច គឺពឹងទៅលើអ្វីដែលយើងមាន និងអ្វីដែលយើងអាចយកចូលទៅក្នុងជម្លោះនោះបាន។

- ខ្ញុំមានផ្លូវផ្សេងសម្រាប់ដើរហើយ។ ខ្ញុំឈ្លោះជាមួយប្រធានក្រុមហ៊ុនរបស់ខ្ញុំ ដោយលើកពីចំណុចដែលខ្ញុំមិនពេញចិត្ត និងថាឱ្យគាត់ចំៗតែម្តង។ ខ្ញុំនិយាយពាក្យក្នុងចិត្តចេញមកទាំងអស់ ដូច្នេះប្រធានរបស់ខ្ញុំបានត្រឹមតែនៅស្ងៀមប៉ុណ្ណោះ ព្រោះបុគ្គលិកដែលគាត់ជួលមក សុទ្ធតែជាប្រភេទ Yes-men និងមនុស្សដែលមិនហ៊ាននិយាយពាក្យក្នុងចិត្តខ្លួនឯង។ តែមុននឹងខ្ញុំទៅនិយាយ ខ្ញុំមានការងារថ្មីរួចទៅហើយ ដូច្នេះមិនថាគេធ្វើយ៉ាងម៉េចចំពោះខ្ញុំទេ ខ្ញុំមានផ្លូវដើរផ្សេងទៀត។ **កុំបង្កជម្លោះ ទាំងគ្មានផ្លូវដើរ**។
- ខ្ញុំអាចទទួលបានប្រយោជន៍ពីជម្លោះនេះ។ ប្រយោជន៍អាចជា លុយកាក់ សេរីភាព បទពិសោធន៍ ការនិយាយឱ្យធូរចិត្ត ភាពស្មោះត្រង់ ការបញ្ចេញកំហឹង ដំណោះស្រាយ ឬដើម្បីបំបាត់ការអផ្សុក។ បើសិនជាប្រយោជន៍ណាមួយគ្រប់គ្រាន់សម្រាប់ខ្ញុំហើយ ខ្ញុំមិនដកថយទេ។ ទោះបីជាខ្ញុំចាញ់ក៏ដោយ តែខ្ញុំនឹងបានប្រយោជន៍ទាំងនេះ។

បើខ្ញុំគិតហើយ តែមិនឃើញមានចំណុចទាំងបីនេះទេ ខ្ញុំមិនឈ្លោះជាដាច់ខាត ព្រោះវាអត់ន័យ។

មានមនុស្សមួយចំនួនដែលខ្ញុំមិនឈ្លោះជាមួយ ដូចជា អ្នកដែលត្រូវនយោបាយបោកប្រើ អ្នកដែលងប់នឹងសាសនា មនុស្សអត់ខួរ និងអ្នកដែលមិនចូលចិត្តសៀវភៅរបស់ខ្ញុំ។

មនុស្សទាំងនេះគ្មានអ្វីអស្ចារ្យដែលធ្វើឱ្យខ្ញុំត្រូវចំណាយពេលទៅឈ្លោះជាមួយពួកគេទេ។

## ៣-៣ ការគិតទុកមុនឱ្យបានច្រើនជំហាន

សមត្ថភាពពិសេសមួយរបស់ខួរក្បាល គឺវាអាចគិតទុកបានច្រើនលើសពីពេលបច្ចុប្បន្ន។ ពេលមានជម្លោះ យើងត្រូវប្រើខួរក្បាលរបស់យើង គិតរកផ្លូវដោះស្រាយឱ្យបានច្រើនជំហានទៅមុខ ឬអាចគិតឱ្យបានច្រើនផ្លូវដើម្បីជៀសវាងផ្លូវណាមួយមិនសមតាមបំណង។ យើងកាន់តែគិតបានច្រើនជំហាន យើងកាន់តែមានសង្ឃឹមឈ្នះច្រើន។

កុំទៅឈ្លោះជាមួយគេ ដោយគិតថា ខ្លួននឹងចាញ់ ព្រោះបើធ្វើបែបនេះ ខួរក្បាលយើងនឹងទទួលលទ្ធផលមុនដោយមិនបានគិតអីទាំងអស់។ **កុំយកទ្រឹស្តី "ចាញ់ជាព្រះ" មកប្រើ ព្រោះលើលោកនេះគ្មានព្រះទេ**។ ទ្រឹស្តីនេះ ជាការបង្កើតរបស់អ្នកមានអំណាចពីជំនាន់មុន ដើម្បីធ្វើឱ្យមនុស្សដែលនៅថ្នាក់ក្រោមស្ងប់ចិត្តមិនរើបម្រះ ហើយពួកគេនឹងជិះសេះលេងដៃមិនខាន។

គ្រូបង្រៀនម្នាក់នៅសាលាឯកជន មានជម្លោះជាមួយនឹងនាយកសាខា ហើយបញ្ហាគឺ យកលុយទៅសូកពេលសិស្សប្រលង។ នាយកសាខា យកលុយពីសិស្សដើម្បីទៅឱ្យសាលារដ្ឋដើម្បីបានពិន្ទុសិស្សខ្ពស់ ទុកយកទៅអួតគេ ពេលផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍។ យើងដឹងថា ការផ្សាយពាណិជ្ជកម្មគឺជាការបោកប្រាស់ ដូច្នេះដើម្បីបានអំពើអាក្រក់មួយ គេត្រូវធ្វើអំពើអាក្រក់ជាច្រើនទៀតសិន។

គ្រូម្នាក់នោះ ត្រូវដេកគិតសិនថាគួរមានរឿងជាមួយនាយកសាខារបស់ខ្លួន ឬអត់។ បើគាត់មានរឿង គាត់នឹងបាត់បង់ការងារមិនខាន ព្រោះនាយកប្រភេទយកលុយពីសិស្សបែបនេះ មិនមែនជាមនុស្សល្អទេ។ ក្រោយគិតទុកប៉ុន្មានថ្ងៃហើយ គាត់ក៏ទៅនិយាយគ្នាទល់មុខ ជាមួយនាយកសាខានោះ ដើម្បីយកចាញ់ឈ្នះ។ ចុងក្រោយ គាត់ត្រូវបាត់បង់ការងារមែន ប៉ុន្តែគាត់បានទៅបង្រៀននៅសាខាផ្សេងទៀតរបស់សាលា ព្រោះគាត់បានទាក់ទងទៅខាងសាខាផ្សេងទៀត មុនពេលគាត់ទៅឈ្លោះគ្នាហើយ។ គាត់គិតដឹងហើយថា បើឈ្លោះរួច គាត់នឹងគ្មានឱកាសមកបង្រៀននៅសាខានេះទៀតទេ ទោះបីជានាយកនោះត្រូវគេដកចេញក៏ដោយ។ គាត់ក៏មិនមកបង្រៀនតាមអ្វីដែលគាត់គិតទុកមែន។

នេះជារឿងពិតមួយដែលខ្ញុំដឹង ហើយអ្នកទាំងអស់គ្នាអាចទាយបានថា តើហេតុអីបានជាខ្ញុំដឹងរឿងនេះ។ តាមពិតខ្ញុំដឹងច្រើនជាងនេះ តែវាចាកប្រធានបើសិនជាយកមកនិយាយទាំងអស់។ ចំណុចនេះ គឺនិយាយពីការគិតជាជំហានមុនពេលមានជម្លោះប៉ុណ្ណោះ។

បើសិនជាយើងគិតមិនបានច្រើនជំហានទេ សូមកុំអាលអន់ចិត្តនឹងខ្លួនឯង។ មិនមែនយើងមានខួរក្បាលមិនល្អទេ តែដោយសារយើងមិនធ្លាប់គិតប៉ុណ្ណោះ ហេតុនេះទើបវាធ្វើការយឺតបន្តិច។ បើយើងទម្លាប់គិតច្រើន ពេលមានជម្លោះយើងនឹងមានជំហានដោះស្រាយកាន់តែច្រើនដែរ។

**កុំប្រញាប់ចូលទៅក្នុងជម្លោះពេក ទុកពេលដើម្បីគិតសិន ព្រោះបើប្រញាប់ពេល យើងអាចក្លាយជាប្រយោជន៍របស់អ្នកដទៃក៏ថាបាន។** មុនខ្ញុំមានរឿងជាមួយ គ ម ល ខ្ញុំក៏បានគិតមុនដែរ តើខ្ញុំនឹងធ្វើអ្វីបន្តទៀត? មុនខ្ញុំមានរឿងជាមួយនឹងអ្នកធ្វើការជាមួយខ្ញុំ ខ្ញុំក៏គិតមុនដូចគ្នា ហើយគិតច្រើនទៀតផង។

## ៣-៤ កម្លាំងក៏ប្រើ ខួរក្បាលក៏ប្រើ

កម្លាំង និងខួរក្បាល ជាអ្វីដែលយើងត្រូវប្រើក្នុងជម្លោះ។ កម្លាំងនេះសំដៅទៅលើ កម្លាំងកាយ ចិត្ត អំណាច ឬកម្លាំងលុយ។ កម្លាំងទាំងនេះមានប្រយោជន៍ណាស់ ពេលមានជម្លោះ។ ប៉ុន្តែបើមានតែកម្លាំង តែខួរក្បាលមិនល្អ ក៏ពិបាកនឹងថាដែរ។

ពេលដែលនិយាយពីជម្លោះ អ្នកនយោបាយ ជាឧទាហរណ៍ល្អបំផុត។ មុនពេលអ្នកនយោបាយបង្កើតជម្លោះជាមួយអ្នកណាម្នាក់ ពួកគេបានត្រៀមខ្លួនជាស្រេច ដោយបង្កើតលេសជាច្រើនទុកសម្រាប់ធ្វើឱ្យភាគីម្ខាងទៀតជាអ្នកខុស។ ក្រៅពីនេះគេនៅរៀបចំផ្លូវដើរផ្សេងទៀតទុកក្រោយពេលជម្លោះ។ ប្រយោជន៍ទាំងអស់ នឹងបានទៅអ្នកនយោបាយ ព្រោះជម្លោះជាជំនាញពិសេសរបស់ពួកគេ។

ប្រធានាធិបតី ប៊ូស របស់សហរដ្ឋអាមេរិច បានបង្កើតពាក្យកុហកជាច្រើនដើម្បីបង្កជម្លោះជាមួយប្រទេសអ៊ីរ៉ាក់ ក្នុងគោលបំណងឈ្លានពាន និងយកប្រេងរបស់គេ។ ពាក្យកុហកនេះទើបនឹងត្រូវគេដឹងក្រោយពេលសង្គ្រាមចប់ ព្រោះអ្វីដែលប៊ូសអះអាងមុនពេលសង្គ្រាម គឺជាប្រឌិតរបស់គាត់ទាំងអស់។ ជម្លោះដែលអាមេរិចចង់បាននេះ ជាជម្លោះដែលអ៊ីរ៉ាក់មិនអាច

មានផ្លូវយកឈ្នះ ដូច្នេះអាមេរិចដែលជាប្រទេសសម្បូរទៅដោយមនុស្សឆ្លាតៗ តែលោភលន់ មិនលើកលែងឱ្យឱកាសចំណេញដ៏ធំនេះទេ។

អាមេរិច មានទាំងកម្លាំង និងមានទាំងខួរក្បាល ដូច្នេះសង្គ្រាមដែលមិនគួរនឹងមាននេះបានដឹងអ្នកឈ្នះអ្នកចាញ់រួចហើយ។ សង្គ្រាមនេះបានបំផ្លាញអ៊ីរ៉ាក់យ៉ាងធ្ងន់ធ្ងរ។ អ្នកដែលស្លាប់ក៏ស្លាប់ ហើយអ្នកដែលនៅរស់ ក៏រស់ដូចស្លាប់ដែរ។ នៅក្នុងសាសនាគ្រឹស្ត គេចាត់ទុកមនុស្សដែលនៅរស់ក្រោយសង្គ្រាមនោះស្ថិតក្នុង Trauma (មានបញ្ហាផ្លូវចិត្ត)។ ពួកគេត្រូវការការព្យាបាលជាបន្ទាន់ ហើយក៏ជាពេលដ៏ល្អបំផុតដែលគ្រឹស្តសាសនាត្រូវចុះទៅពង្រីកប្រជាប្រិយភាពរបស់ខ្លួន។

ខ្ញុំមិនគាំទ្រសង្គ្រាមរបស់អាមេរិចទេ ខ្ញុំលើកវាមកនិយាយព្រោះតែនេះបញ្ជាក់ថា ជម្លោះត្រូវការកម្លាំង និងខួរក្បាល។ យើងក៏ត្រូវប្រើវត្ថុពីរនេះដែរ។ បើកម្លាំងយើងមិនគ្រប់ ហើយខួរក្បាលយើងមិនទាន់គិតអ្វីចេញ កុំទាន់មានជម្លោះ។

## ៣-៥ ស៊ីម៉ាអ៊ី

ក្នុងចំណោមតួអង្គក្នុងរឿងសាមកុក ស៊ីម៉ាអ៊ី ជាតួអង្គមួយដែលខ្ញុំពេញចិត្ត។ ខ្ញុំរៀនពីតួអង្គនេះបានច្រើនគួរសមដែរ ហើយភាគច្រើន គឺប្រើត្រូវជាមួយសង្គមបច្ចុប្បន្នទៀតផង។ ប៉ុន្តែក៏មានមនុស្សមិនតិចដែលមិនចូលចិត្តគាត់។ គេយកស៊ីម៉ាអ៊ី ទៅប្រៀបនឹងជូកឺលាង ហើយគិតថាស៊ីម៉ាអ៊ីជាមនុស្សកំសាកខ្លាចស្លាប់។ ខ្ញុំមិនគិតបែបនេះទេ។

មនុស្សដែលចូលចិត្តជូកឺលាង ច្រើនតែគិតថាខ្លួនឯងជាមនុស្សល្អ ហើយឆ្លាតដូចជូកឺលាង។ ជាពិសេស គឺចរិតខ្ញុំគេ។ អ្នកដែលចូលចិត្តជូកឺលាង មិនភ្លេចពីរំលឹកពីម្ចាស់របស់ខ្លួនឯងទេ សូម្បីតែក្មេងដែលអត់ការងារធ្វើ ក៏យកខ្លួនឯងទៅប្រដូចនឹងជូកឺលាងដែរ។ ពួកគេគិតថា ដោយគ្រាន់តែចូលចិត្តតួអង្គល្អ នឹងធ្វើឱ្យពួកគេខ្លាចតួអង្គល្អដែរ។ មិនអាចទេ។

ក្មេងៗដែលទើបនឹងចេះមើលរឿង និងមិនចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រនៅក្នុងសាលា នឹងវាយតម្លៃតួអង្គតាមរបៀបនេះ។ ប៉ុន្តែក៏មានមនុស្សចាស់ខ្លះ យកគម្រូតាមក្មេងៗដែរ។ **តាមពិតការយកគម្រូតាមក្មេង មិនមែនជារឿងខុសទេ តែត្រូវមើលផងថាគម្រូនោះល្អ ឬមិនល្អ។**

គ្រប់រឿងទាំងអស់ដែលគេចងក្រងមក សុទ្ធតែជាការអប់រំដូច្នេះបើចំណុចណាល្អ យើងយកមកប្រើទៅ ហើយបើចំណុចណាមិនល្អ យើងកុំយកមកប្រើទៅ។ ស៊ីម៉ាអ៊ី អាចមិនមែនជាតួចិត្តល្អ ប៉ុន្តែជាតួអង្គដែលយើងត្រូវរៀនតាម។ ការគិតទុកមុនការប្រយ័ត្នខ្លួន ការបង្រៀនកូនចៅ ការដាក់ខ្លួន ការនិយាយពាក្យពិត និងការស្វែងយល់ពីសត្រូវ សុទ្ធតែជាមេរៀនល្អទាំងអស់។ *ខ្ញុំនឹងសរសេរសៀវភៅពីស៊ីម៉ាអ៊ីនិយាយពីការដាក់ខ្លួនតែសម្រាប់បោះពុម្ពទេ។*

ស៊ីម៉ាអ៊ី មានតួនាទីមកការពារព្រំដែន និងទប់ទល់ជាមួយជូកឺលាង។ ជូកឺលាង ជាអ្នកណាដែរ? ជាទីប្រឹក្សារបស់លីវប៉ី និងត្រូវគេចាត់ទុកជាកំពូលមនុស្សនៅសម័យនោះ។ ចុះស៊ីម៉ាអ៊ីវិញជាអ្នកណា? ជាកូនចៅរបស់ត្រកូលឆាវ ដែលមានប្រាជ្ញា

ខ្លាំងជាមន្ត្រីដទៃប៉ុណ្ណោះ។ ដូច្នេះស៊ឺម៉ាអ៊ី មិនមែនមិនដឹងថា ខ្លួនចាញ់ជូកឺលាងនោះទេ។ បើដឹងថាមិនឈ្នះហើយ ហេតុអ្វីត្រូវចេញច្បាំងទៀត។

ល្បិចរបស់ជូកឺលាង តើមានអ្នកណាអាចគេចផុតដែរទេ? ជូកឺលាងប្រើល្បិចបន្តកន្ទុយគ្នារហូត ស៊ឺម៉ាអ៊ីខ្លាចត្រង់នេះជាងគេ។ ហេតុនេះ ការគេចច្បាំង ជាផ្លូវតែមួយគត់។ ទោះមិនបានជ័យជម្នះ តែក៏មិនមានដំណឹងបរាជ័យដែរ។

ស៊ឺម៉ាអ៊ី អាចប្រើជញ្ជាំងក្រុងខ្ពស់ៗរបស់នគរវ៉ី ដើម្បីការពារខ្លួនបាន។ ជូកឺលាង មិនអាចវាយបាន មានតែបកក្រោយវិញប៉ុណ្ណោះ។ នេះជាវិធីសាស្ត្រច្បាំងជាមួយសត្រូវខ្លាំងជាង។ ជូកឺលាង មានប្រាជ្ញា មានស្បៀង និងមានទ័ពខ្លាំងមកជាស្រេច ឱ្យតែខាងស៊ឺម៉ាអ៊ីហ៊ានចេញទ័ព រឿងនឹងចប់ភ្លាម។

ដូច្នេះទើបយើងឃើញ នៅចុងបញ្ចប់រឿង ស៊ឺម៉ាអ៊ីចេញទ័ព ក៏ត្រូវជាប់អន្ទាក់ក្នុងជ្រោះរបស់ជូកឺលាងទាំងអស់។ បើកុំតែបានភ្លៀង កុំអីឆេះស្លាប់ក្នុងជ្រោះនោះទៅហើយ។ ស៊ឺម៉ាអ៊ីក្រោយមកក៏បានប្រដៅកូនចៅខ្លួនឯងថា "**ទោះជាពេលណា ក៏ត្រូវតែទុកផ្លូវក្រោយមួយដែរ**"។ សង្គ្រាម ជាមួយជូកឺលាង មើលឃើញលទ្ធផលរួចជាស្រេច បើយើងគិតតែបន្តិច។ ជូកឺលាង យកឈ្នះអ្នកណាខ្លះ យើងសុទ្ធតែបានឃើញហើយ ដូច្នេះស៊ឺម៉ាអ៊ីគ្រាន់តែជាមនុស្សម្នាក់ដែលជូកឺលាងអាចយកឈ្នះប៉ុណ្ណោះ។ តែបើស៊ឺម៉ាអ៊ីគេចច្បាំង ប្រហែលជាអាចឈ្នះ។

សង្គ្រាមក៏ដោយ ជម្លោះក៏ដោយ គឺធ្វើក្នុងគោលបំណងយកឈ្នះ មិនមែនដើម្បីយកមុខមាត់ ព្រោះវាមិនមែនជារឿងតូច។

បើឈ្លោះគ្នាក្នុងលក្ខណៈបុគ្គល វាមិនជាបញ្ហាទេ ចុះបើដល់ថ្នាក់សង្គ្រាម តើអ្នកណាសុខចិត្តចេញច្បាំងទាំងដឹងថាខ្លួនឯងគ្មានសង្ឃឹមឈ្នះនោះ?

# ទំព័រចុងក្រោយ

យើងមកដល់ចំណុចបញ្ចប់នៃសៀវភៅនេះហើយ។ ខ្ញុំសង្ឃឹមថាអ្នកដែលបានអានហើយ នឹងយកចរិតទាំងបីដែលនៅក្នុងខ្លួនឆ្កែទៅដាក់ក្នុងខ្លួនឯងផង។ **ចរិតឆ្កែ នឹងធ្វើឱ្យភាពជាមនុស្សរបស់យើង កាន់តែមានតម្លៃ។**

ភាពស្មោះត្រង់ ការចេះការពាររបស់ខ្លួនឯង និងការគិតឱ្យបានដិតដល់មុននឹងហាក់ចូលក្នុងជម្លោះ គឺជាមេរៀនដ៏ល្អដែលយើងមើលរំលង។ សៀវភៅរបស់ខ្ញុំ គ្រាន់តែជាការរំលឹកឡើងវិញប៉ុណ្ណោះ មិនមែនជាវិធីសាស្ត្រ ឬក្បួនខ្នាតអ្វីធំដុំទេ។ អានលេងទៅ តែយកទៅធ្វើមែនទែនផង។

អរគុណ សម្រាប់អ្នកដែលបានជួយទិញសៀវភៅរបស់ខ្ញុំដែលដាក់លក់តាមទីផ្សារ និងអ្នកដែលអានសៀវភៅរបស់ខ្ញុំទាំងអស់ផងដែរ។

ខ្ញុំមានសំណូមពរមួយចុងក្រោយ គឺ កុំចែករំលែកសៀវភៅនេះទៅឱ្យអ្នកដទៃ ព្រោះសៀវភៅនេះមិនមែនជារបស់ free ទេ។ ខ្ញុំធ្វើឡើងក្នុងគោលបំណងរបស់ខ្ញុំ ដូច្នេះសូមគោរពស្នាដៃអ្នកដទៃផង។ ការចែករំលែកជារឿងល្អ ប៉ុន្តែបើយើងយករបស់អ្នកដទៃទៅចែករំលែក ហើយធ្វើឱ្យខូចប្រយោជន៍គេ វានឹងទៅជារឿងភ្លើវិញមិនខាន។

ចរិតឆ្កែរបស់ខ្ញុំបានបង្ខំខ្ញុំឱ្យនិយាយតាមត្រង់ថា **"បំផ្លាញអ្នកនិពន្ធក្នុងស្រុករបស់ខ្លួន ជាទង្វើរបស់មនុស្សភ្លើប៉ុណ្ណោះ"**។ ការ Copy ចែកគ្នា ជាការសម្លាប់អ្នកនិពន្ធដែលរកលុយបានតិច

ស្រាប់។ កុំភ្លេចណា **អ្នកនិពន្ធមិនមែនស៊ីអក្សរឆ្អែតទេ ទោះបីជាពួកគេស្រលាញ់ការសរសេរសៀវភៅប៉ុណ្ណាក៏ដោយ** ហើយបើមិនជួយគាំទ្រទេ កុំបំផ្លាញគេ។

# អំពីខ្ញុំ

ខ្ញុំឈ្មោះ ហួត សេងគៀ។ ខ្ញុំធ្វើការក្នុងផ្នែកក្រាហ្វិចឌីហ្សាញនៅភ្នំពេញនេះឯង។ ក្រៅពីឌីហ្សាញ ខ្ញុំនៅមានចំណូលចិត្តមួយទៀត គឺការសរសេរ។ ខ្ញុំសរសេរប្លុក សៀវភៅ និងនៅលើហ្វេសប៊ុក។

ខ្ញុំចង់យកអ្វីដែលមានក្នុងខួរក្បាលរបស់ខ្ញុំ ឱ្យអ្នកដទៃអាន។ ខ្ញុំមានអារម្មណ៍ថា ក្បាលខ្ញុំរីកធំ បើខ្ញុំដឹងអ្វីហើយ មិនយកវាចេញមកក្រៅ។ ខ្ញុំមិនចង់បានក្បាលធំពេកទេ ពិបាកពាក់មួកសុវត្ថិភាព។

សូមអរគុណអ្នកទាំងអស់គ្នាដែលមិនប្រកាន់ខ្លួនអានសៀវភៅរបស់ខ្ញុំ។ ការអានរបស់អ្នករាល់គ្នា ជាការផ្តល់កម្លាំងចិត្តដល់ការសរសេររបស់ខ្ញុំ។